ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការចិញ្ចឹមត្រីក្នុងស្រែ




រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ រដ្ឋបាលជលផល



ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយៈ លោក ជិន ដា**

**រដ្ឋបាលជលផល**

ទូរស័ព្ទលេខៈ ០២៣ ៩៩៦ ៣៨០ ឬ ០១១៩៩០៩៩០

អ៊ីម៉ែលៈ smallfish@online.com.kh

**កាលបរិច្ឆេទៈ ខែ តុលា ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះជាកម្មសិទ្ធិរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID)តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជាបានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Suject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹងព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និងផលិតករ ដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខណ្ឌភូមិសាស្រ្ត សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការ ចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្រ្ត ចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះដែលជា ឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ "បទដ្ឋានអនុវត្តបច្ចេកវិទ្យា"។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យាដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់អោយមន្រ្តីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្រ្តីផ្សព្វផ្សាយអង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀត ដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៍កសិកម្ម នៅតាមមូលដ្ឋានប្រើប្រាស់។ បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករ តាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗ របស់កសិករ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធ កសិ្សត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំង ព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ននានាដូច ខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអបត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័ត និង អនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

# មាតិកាអត្ថបទ


**១~ សេចក្តីផ្តើម**

**២~ គោលការណ៍បច្ចេកទេស**

២.១- ហេតុអ្វីយើងចាំបាច់ចិញ្ចឹមត្រីក្នុងស្រែ ?

២.២- ការជ្រើសរើសទីកន្លែង សម្រាប់អភិវឌ្ឍន៍ការចិញ្ចឹមត្រីក្នុងស្រែ

២.២.១- លក្ខណៈប្រភពទឹក

២.២.២- លក្ខណៈតំបន់អភិវឌ្ឍន៍ការចិញ្ចឹមត្រីក្នុងស្រែ

២.២.៣- លក្ខណៈសេដ្ឋកិច្ចសង្គម

២.៣- ការជ្រើសរើសកសិករ សម្រាប់ផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ

២.៤- ការរៀបចំស្រែ សម្រាប់ចិញ្ចឹមត្រី

២.៤.១- ការរៀបចំភ្លឺស្រែ

២.៤.២- ការដាក់បំពង់បង្ហូរទឹកចេញ-ចូល

២.៤.៣- ការរៀបចំជម្រកត្រីក្នុងស្រែ

២.៤.៣.១- ការជីកប្រឡាយក្នុងស្រែ

២.៤.៣.១- ការជីកស្រះក្នុងស្រែ

២.៤.៣.១- ការជីកស្រះភ្ជាប់ទៅវាលស្រែ

២.៥- ការចិញ្ចឹមត្រីក្នុងស្រែ និងការគ្រប់គ្រង

២.៥.១- ការរៀបចំស្រះ និងស្រែ មុនដាក់ត្រីចិញ្ចឹម

២.៥.១.១- ការសំអាតស្មៅ និងរុក្ខជាតិក្នុងស្រែ

២.៥.១.១.-ការបាចកំបោរ

២.៥.១.២-ការដាក់ជី

២.៥.១.៣-ការគ្រប់គ្រងគុណភាពទឹក

២.៥.២- ការដាក់ត្រីចិញ្ចឹមក្នុងស្រែ

២.៥.២.១-ប្រភេទត្រីដាក់ចិញ្ចឹម

២.៥.២.២-ចំនួនកូនត្រីដាក់ចិញ្ចឹម

២.៥.៣- ចំណី និងការផ្តល់ចំណីបន្ថែម

២.៥.៤- ការត្រួតពិនិត្យគុណភាពទឹក

២.៥.៥- ការគ្រប់គ្រងត្រី និងស្រូវ

២.៥.៦- ប្រភេទស្រូវ

២.៥.៧- ការគ្រប់គ្រងស្មៅ និងសត្វល្អិតចង្រៃក្នុងស្រែ

២.៥.៧.១- ការគ្រប់គ្រងស្មៅ និងសត្វល្អិតចង្រៃក្នុងស្រែចិញ្ចឹមត្រី

២.៥.៧.២- ការគ្រប់គ្រងស្មៅ និងរុក្ខជាតិចង្រៃ

២.៥.៧.៣- ការគ្រប់គ្រងជំងឺត្រី

២.៥.៧.៤- ការការពារជំងឺត្រី

២.៦- ការប្រមូលផលត្រី និងស្រូវ

២.៦.១- ការប្រមូលផលត្រី

២.៦.២- ការប្រមូលផលស្រូវ

២.៧- ការលក់ផលត្រីចិញ្ចឹម

២.៨- ការវិភាគសេដ្ឋកិច្ច

## ៣. វិធីសាស្ត្រផ្សព្វផ្សាយ

៣.១- ការសិក្សាទីផ្សារ

៣.២- ការផ្សព្វផ្សាយបច្ចេកទេស

៣.៣- ការចំណាយសម្រាប់ការធ្វើបង្ហាញ

៣.៤- ការចូលរួមរបស់ស្ត្រី ក្នុងសកម្មភាពវារីវប្បកម្ម

## ៤. សេចក្តីបន្ថែម

៤.១- បញ្ហាដែលកើតមានក្នុងពេលចិញ្ចឹមត្រីក្នុងស្រែ និងវិធានការដោះស្រាយ

៤.២- តារាងប្រមូលទិន្នន័យ

## ១- សេចក្តីអធិប្បាយ

**សេចក្តីសង្ខេប**

**បញ្ហា** កសិករមិនចេះបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ

**គោលដៅ** បង្កើនប្រាក់ចំណូលពីផលិតផលត្រី និងស្រូវ និងកាត់បន្ថយការខ្វះខាតអាហារូបត្ថម្ភរបស់ប្រជាកសិករ តាមរយៈការកែលំអបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ ។

**វិធីសាស្ត្រ**
១- ការរៀបចំស្រែ មុនពេលស្ទូង និងដាក់កូនត្រីចិញ្ចឹម
២- ការជ្រើសរើសគុណភាពកូនត្រីពូជ (មានទំហំធំ និងមានសុខភាពល្អ) ដាក់ចិញ្ចឹមក្នុងស្រែ
៣- ការគ្រប់គ្រងកូនត្រីចិញ្ចឹមក្នុងស្រែ រហូតដល់ពេលប្រមូលផល
៤- ការត្រួតពិនិត្យគុណភាពទឹក
៥- ការគ្រប់គ្រងការផ្តល់ចំណី និងការប្រើប្រាស់ជី ។

**អត្ថប្រយោជន៍**

- បង្កើនប្រាក់ចំណូលក្នុងគ្រួសារ តាមរយៈការចិញ្ចឹមត្រីក្នុងស្រែ
- គ្រួសារកសិករមានត្រីហូបគ្រប់គ្រាន់ (សន្តិសុខស្បៀង)
- កសិករដែលគ្មានស្រះ ឬគ្មានដីជីកស្រះអាចចិញ្ចឹមត្រីក្នុងស្រែបាន
- កសិករប្រមូលផលត្រីផង និងស្រូវផង ក្នុងពេលតែមួយ
- បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះងាយស្រួលឱ្យកសិករយកទៅអនុវត្ត
- កសិករអាចចិញ្ចឹមត្រីក្នុងស្រែបានដោយប្រើបច្ចេកទេសងាយៗ
- កសិករប្រើប្រាស់ដើមទុនតិចតួច ក្នុងការចិញ្ចឹមត្រីក្នុងស្រែ
- ត្រីចិញ្ចឹមឆាប់ធំ និងស្រូវលូតលាស់បានល្អ ពីព្រោះត្រី និងស្រូវ ផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក
- កាត់បន្ថយការចំណាយ ទិញចំណីត្រី និងទិញជីដាក់ស្រែ
- ការចិញ្ចឹមត្រីក្នុងស្រែ អាចបញ្ឈប់ការប្រើប្រាស់គីមីកសិកម្ម ដែលអាចធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស
- បង្កើនការងារកសិកម្ម ដែលផ្តល់ពហុប្រយោជន៍ សម្រាប់កសិករ
- មិនចាំបាច់ចំណាយពេលចាប់ត្រីពីធម្មជាតិ សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ
- កាត់បន្ថយការចាប់ត្រីពីធម្មជាតិ ។

**លក្ខខណ្ឌអំណោយផលនៃបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ**

លក្ខណៈវិនិច្ឆ័យខាងក្រោមនេះ ជាលក្ខខណ្ឌចាំបាច់ ក្នុងការអនុវត្តបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដើម្បីសម្រេចបាន ដូចគោលបំណងដែលបានរៀបរាប់ខាងលើ ៖

## លក្ខណៈអាកាសធាតុ និង ទឹកសម្រាប់ចិញ្ចឹមត្រីក្នុងស្រែ

- ស្រែចិញ្ចឹមត្រីគួរនៅជិតប្រភពទឹក ដើម្បីងាយស្រួលបូមទឹកបញ្ចូលស្រែចិញ្ចឹមត្រី
- ស្រែចិញ្ចឹមត្រីមិនត្រូវឱ្យលិចទឹកនៅរដូវវស្សា ដើម្បីជៀសវាងត្រីចិញ្ចឹមរួចចូលក្នុងតំបន់ទឹកធម្មជាតិ និងការពារកុំឱ្យខាតបង់ចរិកា
- ស្រែចិញ្ចឹមត្រីគួរនៅជិតផ្ទះ ដើម្បីងាយស្រួលគ្រប់គ្រង
- ដីអាចដក់ទឹកបានយូរ ដើម្បីងាយស្រួលចិញ្ចឹមត្រី និងដាំដំណាំស្រូវ
- ស្រែចិញ្ចឹមត្រី គួរនៅឱ្យឆ្ងាយពីតំបន់ដែលមានប្រើប្រាស់ថ្នាំពុល ដូចជា ថ្នាំសម្លាប់សត្វល្អិត
- អាកាសធាតុប្រទេសកម្ពុជា មានលក្ខណៈអំណោយផលល្អ សម្រាប់ការចិញ្ចឹមត្រីក្នុងស្រែ។

## លក្ខណៈភូមិសាស្ត្រ

- ការចិញ្ចឹមត្រីក្នុងស្រែចាំបាច់ត្រូវយកចិត្តទុកដាក់អនុវត្តតាមលក្ខខណ្ឌ ដែលបានថែងខាងលើ
- ការអនុវត្តតាម (បទដ្ឋានអនុវត្តបច្ចេកវិទ្យា)នេះបានជោគជ័យ ក៏អាស្រ័យនឹងការជ្រើសរើសកសិករដែលមានសមត្ថភាពអនុវត្តបច្ចេកទេសដូចក្នុងសៀវភៅនេះ ។

## ទំហំកសិដ្ឋាន

ស្រែចិញ្ចឹមត្រីគួរមានទំហំយ៉ាងហោចណាស់ ៥០០ ម² និងជាប្រភេទដីអាចដក់ទឹកបានរយៈពេលយូរ។ ទំហំដីស្រែកាន់តែធំ បរិមាណកូនត្រីដាក់ចិញ្ចឹមបានច្រើន ហើយក៏ទទួលផលត្រី និងស្រូវបានកាន់តែច្រើនផងដែរ ។ ជាទូទៅស្រែនៅតាមជនបទមានទំហំពី ៥០០- ៥,០០០ម² ស្រែដែលមានទំហំតូចជាងនេះ ក៏អាចចិញ្ចឹមត្រីបានដែរ ប៉ុន្តែបរិមាណផលត្រីទទួលបានតិចជាងស្រែដែលមានទំហំធំ។

## តម្រូវការកម្លាំងពលកម្ម

- ការចិញ្ចឹមត្រីក្នុងស្រែជាលក្ខណៈគ្រួសារ នៅតាមជនបទ អាចអនុវត្តបានដោយប្រើប្រាស់កម្លាំងពលកម្មក្នុងគ្រួសារ
- ដូចជា ការរៀបចំស្រះ និងការដឹកជញ្ជូនកូនត្រីពូជ អនុវត្តដោយកម្លាំងបុរស
- ការលក់ត្រីសាច់ និងផលិតផលស្រូវ ជាធម្មតាស្ត្រីជាអ្នកអនុវត្ត
- សកម្មភាពអនុវត្តដទៃទៀត ដូចជា ការជីកស្រះ ជីកប្រឡាយ ឬចង្អូរ ការលើកភ្លឺស្រែ ស្ទូងស្រូវ ការដាក់កូនត្រីចិញ្ចឹម ការផ្តល់ចំណី និងជី ការត្រួតពិនិត្យមើលត្រីក្នុងស្រែ និងការប្រមូលផលត្រី និងស្រូវច្រើនធ្វើឡើងដោយកម្លាំងពលកម្ម រួមគ្នាដែលមានក្នុងគ្រួសារ ។

## ស្ថានភាពសេដ្ឋកិច្ចនៃការចិញ្ចឹមត្រីក្នុងស្រែរបស់កសិករ

ការចិញ្ចឹមត្រីក្នុងស្រែជាលក្ខណៈគ្រួសារកសិករអាចប្រើប្រាស់ទុន ៧០.០០០៛- ១០០,០០០៛ ក្នុងករណីកសិករមិនចំណាយទៅលើការជីកស្រះ ប្រឡាយ លើកភ្លឺស្រែ ពូជស្រូវ និងជីធម្មជាតិ។ ទុននេះសម្រាប់ចំណាយទៅលើការរៀបចំស្រះ បូមទឹក ការទិញកូនត្រី និងទិញចំណីត្រី សម្រាប់ចិញ្ចឹមត្រីក្នុងស្រះ ១០០ម² ភ្ជាប់ទៅ

ស្រែដែលមានទំហំ ១.០០០ម² ចិញ្ចឹមក្នុងរយៈពេល ៤ខែ (សូមអានចំណុចទី ២.៨)។ ការចំណាយនេះនឹងអាចអនុវត្តសកម្មភាពចិញ្ចឹមត្រីក្នុងស្រែតាមការណែនាំ (បទដ្ឋានអនុវត្តបច្ចេកវិទ្យា) នេះ។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**


ការិយាល័យវារីវប្បកម្ម រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩៩៦ ៣៨០ អ៊ីម៉ែល: smallfish@online.com.kh

## ២-គោលការណ៍បច្ចេកទេស

### ២.១- ហេតុអ្វីយើងចាំបាច់ចិញ្ចឹមត្រីក្នុងស្រែ ?

ប្រទេសកម្ពុជាមានការប្រែប្រួលបរិស្ថាន និងធនធានធម្មជាតិ ដែលនាំឱ្យមានការថយចុះ ផលិតផលធន-ធានជលផល។ ការថយចុះធនធានជលផលនេះបានជំរុញឱ្យកសិករជាច្រើនចាប់ផ្តើមការចិញ្ចឹមត្រី ។ វារីវប្បកម្មបាន និងកំពុងបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមវិភាគទានដល់ផលិតផលត្រីទូទាំងប្រទេស និងជួយដល់សន្តិសុខស្បៀង។ គេបានកត់សំគាល់ថា នៅឆ្នាំ ២០០៥ ផលិតផលវារីវប្បកម្មទទួលបាន ២៦.០០០ តោន គឺស្មើប្រហែល ៧% នៃផលិតផលត្រី សរុបដែលមាន ៤១០.០០០ តោន នៅឆ្នាំ ២០០៥។ ផលិតផលវារីវប្បកម្មឆ្នាំ ២០០៥ នេះបានបង្ហាញឱ្យឃើញនូវកំណើនយ៉ាងខ្លាំង បើប្រៀបធៀបផលិតផលវារីវប្បកម្មឆ្នាំ ១៩៨៤ ដែលមានតែ ១.៦១០តោន ប៉ុណ្ណោះ។ នេះបញ្ជាក់ថាសកម្មភាពវារីវប្បកម្មកំពុងមានការរីកចំរើនយ៉ាងរហ័សពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសការអភិវឌ្ឍន៍វារីវប្បកម្មជាលក្ខណៈគ្រួសារដែលកំពុងមានសារៈសំខាន់បំផុត ក្នុងការចូលរួមជួយលើកស្ទួយជីវភាពរស់នៅរបស់ប្រជាកសិករក្រីក្រ។

បច្ចុប្បន្ននេះ មានកសិករជាច្រើនគ្រួសារ កំពុងចូលរួមសកម្មភាពចិញ្ចឹមត្រី នៅក្នុងតំបន់រស់នៅរបស់ខ្លួន ជាពិសេសតំបន់នៅឆ្ងាយពីដែនទឹកធម្មជាតិ ដែលគ្មានផលត្រីធម្មជាតិគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការហូបចុក ។ ដូចនេះ ការចិញ្ចឹមត្រីក្នុងស្រែ ពិតជាមានសារៈសំខាន់ ក្នុងការចូលរួមដល់ការអភិវឌ្ឍន៍សកម្មភាពវារីវប្បកម្ម។ បច្ចុប្បន្នសកម្មភាពការចិញ្ចឹមត្រីក្នុងស្រែកំពុងត្រូវបានទទួលការគាំទ្រពីរាជរដ្ឋាភិបាល សហការជាមួយបណ្តាអង្គការជាតិ និងអន្តរជាតិនានា ដូចជា PADEK, AIT-AARM, SCALE, MRC-AIMS, WFP, CRS, JICA ។ល។ ទោះជាយ៉ាងណាក៏ដោយក៏នៅតែទាមទារឱ្យមានការជួយគាំទ្រឱ្យបានខ្លាំងក្លាបន្ថែមទៀត ក្នុងការជួយបង្កើនចំណេះដឹងបច្ចេកទេសចិញ្ចឹម និងការគ្រប់គ្រងការចិញ្ចឹមត្រីក្នុងស្រែ ដើម្បីបង្កើនប្រាក់ចំណូល និងដោះស្រាយសន្តិសុខស្បៀងរបស់កសិករក្នុងមូលដ្ឋានជនបទ។

### ២.២- ការជ្រើសរើសទីកន្លែង សម្រាប់អភិវឌ្ឍន៍ការចិញ្ចឹមត្រីក្នុងស្រែ

#### ២.២.១- លក្ខណៈប្រភពទឹក

ជាទូទៅ ការធ្វើស្រែរបស់ប្រជាកសិករពឹងផ្អែកទៅលើទឹកភ្លៀង។ ការចិញ្ចឹមត្រីក្នុងស្រែតម្រូវឱ្យមានស្រះត្រី និងប្រឡាយធំទូលាយ ហើយជ្រៅ ដើម្បីរក្សាទឹកក្នុងស្រះឱ្យបានយូរ យ៉ាងហោចណាស់បានរយៈពេល ៤ ខែ។ ស្រែចិញ្ចឹមត្រីគួរមានទីតាំងនៅជិតប្រភពទឹក ដើម្បីងាយស្រួលបូមទឹកបញ្ចូលស្រែនៅពេលទឹកក្នុងស្រែស្រកចុះ ពិសេសនៅពេលរដូវប្រាំង។ បើមានលទ្ធភាពកសិករគួរមានម៉ាស៊ីនបូមទឹក ឬ ជួលសម្រាប់បូមទឹកបញ្ចូលស្រែ។

#### ២.២.២- លក្ខណៈតំបន់អភិវឌ្ឍន៍ការចិញ្ចឹមត្រីក្នុងស្រែ

ការចិញ្ចឹមត្រីក្នុងស្រែ គួរមានទីតាំងនៅជិតផ្ទះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ឬ ស្ថិតនៅក្នុងតំបន់ដែលនៅឆ្ងាយពីការលួចចាប់ត្រី។ ស្រែចិញ្ចឹមត្រីត្រូវជៀសវាងស្ថិតនៅក្នុងតំបន់លិចទឹក ដើម្បីកុំឱ្យត្រីចិញ្ចឹមដែលជាប្រភេទត្រីក្រៅស្រុក ដូចជា ត្រីទីឡាព្យ៉ា កាបសាមញ្ញ ជាដើម រួចចូលទៅក្នុងតំបន់ទឹកធម្មជាតិ ដែលអាចធ្វើឱ្យប៉ះពាល់ដល់មជ្ឈដ្ឋាន

រស់នៅរបស់ប្រភេទត្រីក្នុងស្រុក។ ម្យ៉ាងទៀត ការចិញ្ចឹមត្រីក្នុងស្រែមិនឱ្យមានការប្រើប្រាស់ថ្នាំពុល ឬ ថ្នាំសម្លាប់សត្វល្អិត ពីព្រោះវាធ្វើឱ្យត្រីស្លាប់។



**២.២.៣- លក្ខណៈសេដ្ឋកិច្ចសង្គម**

គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺមានការគាំទ្រយ៉ាងខ្លាំងដល់ការជំរុញឱ្យមានការអភិវឌ្ឍន៍សកម្មភាពវារីវប្បកម្ម ដើម្បីជួយលើកស្ទួយកំរិតជីវភាពរស់នៅ និងជួយផ្គត់ផ្គង់ដល់សន្តិសុខស្បៀងរបស់ប្រជាកសិករក្រីក្រ។ ការចិញ្ចឹមត្រីក្នុងស្រែ ជាវិធីមួយយ៉ាងសំខាន់ នៃការអភិវឌ្ឍន៍សកម្មភាពវារីវប្បកម្ម ពីព្រោះវាបានជួយបង្កើនប្រាក់ចំណូលបន្ថែមពីលើការធ្វើស្រែ។

**២.៣- ការជ្រើសរើសកសិករ សម្រាប់ផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ**

ខាងក្រោមនេះជាលក្ខណៈវិនិច្ឆ័យសំខាន់ៗ នៃការជ្រើសរើសកសិករ ដើម្បីអនុវត្តសកម្មភាពចិញ្ចឹមត្រីក្នុងស្រែ ដោយផ្អែកលើបទពិសោធន៍ និងការសិក្សាពីការអភិវឌ្ឍន៍វារីវប្បកម្ម។

**បុគ្គលិកលក្ខណៈរបស់កសិករ**

- ជាកសិករឧស្សាហ៍ព្យាយាមមានបទពិសោធន៍ច្រើនលើបច្ចេកទេសចិញ្ចឹមត្រី និងទីផ្សារ
- ពេញចិត្តនឹងការងារចិញ្ចឹមត្រីក្នុងស្រែ និងព្យាយាមធ្វើការងារ
- ចូលរួមសហការការងារជាមួយបុគ្គលិកផ្សព្វផ្សាយរបស់គម្រោង
- មានទំនាក់ទំនងល្អជាមួយប្រជាជនក្នុងភូមិ និងក្រៅភូមិ ។

**ធនធានរបស់កសិករ**

- មានស្រែនៅជិតផ្ទះងាយស្រួលគ្រប់គ្រងការចិញ្ចឹមត្រីក្នុងស្រែ
- ស្រែគួរមានផ្ទៃដី ប្រហែល ៥០០ម២ ដើម្បីយកដីមួយផ្នែកសម្រាប់ជីកស្រះ និងប្រឡាយចិញ្ចឹមត្រីក្នុងស្រែ
- បើមានលទ្ធភាពគួរមានប្រភពទឹក ដើម្បីងាយស្រួលបូមទឹកបញ្ចូលស្រែ ឱ្យមានទឹកធ្វើស្រែ និងចិញ្ចឹមត្រីបានយ៉ាងហោចណាស់រយៈពេល ៤ខែ
- ស្រះ ឬ ប្រឡាយជីកក្នុងស្រែ គួររក្សាទឹកឱ្យបានរយៈពេល ៦ ខែ
- បើមានលទ្ធភាពកសិករគួរមានម៉ាស៊ីនបូមទឹកសម្រាប់បូមទឹកបញ្ចូលស្រែ
- មានកម្លាំងពលកម្មគ្រប់គ្រាន់
- មានធនធានចំណីធម្មជាតិ និងជីលាមកសត្វក្នុងភូមិសម្រាប់ចិញ្ចឹមត្រី
- មានទុនសម្រាប់ដំណើរការចិញ្ចឹមត្រីក្នុងស្រែ។

**ធនធានក្នុងភូមិ**

- មានស្រែច្រើន (សមស្របតាមបច្ចេកទេស និងរក្សាទឹកបានពី ៤-៦ខែ) ក្នុងភូមិ ឃុំ សម្រាប់ចិញ្ចឹមត្រី

- មានប្រជាកសិករជាច្រើនក្នុងភូមិ និងក្រៅភូមិ ចាប់អារម្មណ៍ និងចូលរួមការងារចិញ្ចឹមត្រីក្នុងស្រែ
- ខ្វះខាតសាច់ត្រីទទួលទាន ដូចជា ត្រីស្រែ ក្តាម ខ្យង ខ្ចៅ ជាដើមពុំមានសម្បូរនៅរដូវភ្លៀង ឬរដូវប្រាំង ។

## ២.៤- ការរៀបចំស្រែ សម្រាប់ចិញ្ចឹមត្រី

### ២.៤.១- ការរៀបចំភ្លឺស្រែ

ជាធម្មតា ភ្លឺស្រែមានកំពស់ទាបៗ និងមានទំហំតូច ពីព្រោះប្រភេទស្រូវរបស់ប្រជាកសិករដាំមិនត្រូវការទឹកជ្រៅទេ ។ ប៉ុន្តែ ចំពោះស្រែចិញ្ចឹមត្រី ចាំបាច់តម្រូវឱ្យរៀបចំភ្លឺស្រែ តាមរបៀបដូចខាងក្រោម ៖

- ត្រូវរៀបចំលើកភ្លឺស្រែឱ្យមានកំពស់ពី ៥០- ៧០ ស.ម (សូមមើលរូបភាពខាងក្រោម)ដើម្បីកុំឱ្យត្រីស្រែលោតចូលស្រែចិញ្ចឹមត្រី ជាពិសេស នៅក្រោយពេលដាក់កូនត្រីចិញ្ចឹម
- ម្យ៉ាងទៀត ភ្លឺស្រែត្រូវមានទទឹងពី ៤០- ៥០ ស.ម ដើម្បីកុំឱ្យទឹកជ្រាបចេញពីស្រែចិញ្ចឹមត្រី
- កំរិតកំពស់ទឹកក្នុងស្រែ ត្រូវរក្សាឱ្យមានពី ២០- ៣០ ស.ម
- ភ្លឺស្រែត្រូវរៀបចំឱ្យមានបំពង់បង្ហូរទឹកចេញ ចូលស្រែ ដើម្បីជៀសវាងត្រីរួចចេញពីស្រែ ពេលមានភ្លៀងខ្លាំង ។





### ២.៤.២- ការដាក់បំពង់បង្ហូរទឹកចេញ-ចូល

ភ្លឺស្រែដែលមានទំហំធំៗ មិនងាយនឹងទទួលរងការបាក់ខូតខាតឡើយ ក៏ប៉ុន្តែវាទាមទារព្យាយាមថែរក្សាវាឱ្យបានល្អ។ ការដាក់បំពង់បង្ហូរទឹកចេញចូលបង្កប់ក្នុងភ្លឺស្រែចិញ្ចឹមត្រី គឺដើម្បីងាយស្រួលក្នុងការផ្លាស់ប្តូរទឹកចេញចូលស្រែ ដូចជាស្រះចិញ្ចឹមត្រីដែរ ។ ជាទូទៅ បំពង់បង្ហូរទឹកចេញចូលស្រែ ឬស្រះចិញ្ចឹមត្រី ត្រូវមានភ្ជាប់នៅខាងចុងបំពង់បង្ហូរទឹកចូលស្រែចិញ្ចឹមត្រី នូវសំណាញ់ដែលជាតម្រងកុំឱ្យត្រីស្រែចូលក្នុងស្រែ ឬស្រះចិញ្ចឹមត្រីបាន ។ កសិករអាចប្រើបំពង់ឬស្សី ឬ បំពង់ឈើប្រហោងក្នុង ឬប្រើបំពង់ទឹកជ័រ ទៅតាមលទ្ធភាពកសិករម្នាក់ៗ ដើម្បីងាយស្រួលប្រើក្នុងការបញ្ចេញបញ្ចូលទឹក ។

### ២.៤.៣- ការរៀបចំជម្រកត្រីក្នុងស្រែ

ស្រែចិញ្ចឹមត្រីត្រូវរៀបចំឱ្យមានជាជម្រក ដែលជាកន្លែងមានជម្រៅជ្រៅ សម្រាប់ត្រីរស់នៅបានល្អក្នុងស្រែ ជម្រកទាំងនោះអាចជាស្រះ ឬប្រឡាយជាដើម ។ ការរៀបចំជាជម្រកត្រីក្នុងស្រែចិញ្ចឹមត្រីនេះ មានប្រយោជន៍សម្រាប់ត្រីរស់នៅបាននៅពេលដែលទឹកក្នុងស្រែរីងស្ងួត ឬពុំមានទឹកគ្រប់គ្រាន់សម្រាប់ត្រីរស់នៅ ។ ម្យ៉ាងទៀត វាមានប្រយោជន៍នៅពេលប្រមូលផលស្រូវដែលនៅពេលនោះត្រីចិញ្ចឹមក៏អាចប្រមូលផលផងដែរ ។ មិនតែប៉ុណ្ណោះ វាមានប្រយោជន៍ដល់កសិករដែលចង់ចិញ្ចឹមត្រីក្នុងស្រែបន្តទៀត ក្រោយពេលប្រមូលផលស្រូវរួច ។

 

រូបភាពស្រះ ឬ ប្រឡាយ ក្នុងស្រែ សម្រាប់ជាជម្រកត្រី

### ២.៤.៣.១- ការជីកប្រឡាយក្នុងស្រែ

ការជីកប្រឡាយក្នុងស្រែចិញ្ចឹមត្រី គឺជួយឱ្យត្រីធ្វើចលនាបានស្រួលពីស្រះ ទៅស្រែ ឬ មានប្រយោជន៍នៅពេលទឹកក្នុងស្រែរាក់ ត្រីនឹងមករស់នៅក្នុងប្រឡាយ។ ប្រឡាយគួរជីកឱ្យជ្រៅ មានទំហំមាត់លើពី ៤០- ៥០ ស.ម ឬជីកធំជាងនេះក៏បាន អាស្រ័យនឹងទំហំស្រែ និងជីកឱ្យស្របនឹងជ្រុងទាំង ៤ នៃភ្លឺស្រែ (សូមមើលរូបខាងលើ) ដើម្បីបង្កលក្ខខណ្ឌរស់នៅរបស់ត្រីឱ្យឆាប់ធំធាត់ទាំងនៅរដូវប្រាំង និងរដូវវស្សា។ ការជីកប្រឡាយ ឬស្រះក្នុងស្រែ មិនធ្វើឱ្យប៉ះពាល់ដល់ដំណាំស្រូវទេ។ ជាទូទៅការជីកប្រឡាយក្នុងស្រែចិញ្ចឹមត្រី មានមុខងារ ៣ យ៉ាងដូចខាងក្រោម ៖

- ជាជម្រកត្រី និងរក្សាទឹកក្នុងជម្រកត្រីឱ្យបានយូរ
- បង្កលក្ខខ័ណ្ឌឱ្យត្រីរស់នៅ និងធ្វើចលនាចេញ ចូលទៅស្រែរកចំណីបានស្រួល
- និងជាកន្លែងប្រមូលផលត្រីបានស្រួល។

ប្រឡាយក្នុងស្រែចិញ្ចឹមត្រីអាចជីកបានគ្រប់ទំរង់អាស្រ័យនឹងផ្ទៃស្រែ និងចំណង់ចំណូលចិត្តរបស់កសិករ។

### ២.៤.៣.២- ការជីកស្រះក្នុងស្រែ

ម្យ៉ាងទៀត ក្រៅពីការជីកប្រឡាយក្នុងស្រែ កសិករអាចជីកស្រះបន្ថែមទៀតនៅត្រង់ជ្រុងណាមួយនៃស្រែដើម្បីធ្វើជាជម្រកត្រីផងដែរ។ ការជីកស្រះក្នុងស្រែចិញ្ចឹមត្រីនេះមិនត្រូវធ្វើភ្លឺស្រះទេ ដើម្បីឱ្យស្រះលិចទឹកក្នុងស្រែងាយស្រួលឱ្យត្រីចេញទៅស្រែបាន។ ក្នុងករណី កសិករជីកប្រឡាយមានទំហំធំប្រឡាយនេះក៏អាចចាត់ទុកជាស្រះបានដែរ។ ការជីកស្រះនិងប្រឡាយត្រូវជីកឱ្យភ្ជាប់គ្នាងាយស្រួលឱ្យត្រីចេញចូលឆ្លងទៅស្រះបាន នៅពេលទឹកស្រែរីងក្នុងរដូវប្រាំង ឬ នៅពេលប្រមូលផលត្រី។ ជាទូទៅ ទំហំស្រះ និងប្រឡាយដែលត្រូវជីកក្នុងស្រែ អាស្រ័យទៅនឹងទំរង់នៃស្រែនោះ ប៉ុន្តែវាអាចជីកលើផ្ទៃដីស្រែពី ១៥-២០ភាគរយ ឬជីកតែពី ៥-១០ភាគរយ នៃផ្ទៃស្រែសរុបក៏បាន។ ជម្រៅស្រះដែលត្រូវជីក អាស្រ័យទៅនឹងផ្ទៃស្រះដែលត្រូវជីកឱ្យមានជំរាលជើងទេរស្រះ១ លើ ១។ ក្នុងការអនុវត្តជាក់ស្តែង ទីតាំងជីកស្រះភាគច្រើន គួរជីកនៅកន្លែងដែលទំនាបជាងគេក្នុងស្រែ ដើម្បីងាយស្រួលឱ្យទឹក និងត្រីទៅប្រមូលផ្តុំគ្នាក្នុងស្រះ នៅពេលប្រមូលផលត្រី។

### ២.៤.៣.៣- ការជីកស្រះភ្ជាប់ទៅវាលស្រែ

ការចិញ្ចឹមត្រីក្នុងស្រែ កសិករអាចជីកស្រះក្នុងស្រែក៏បាន ឬ ជីកស្រះនៅក្រៅស្រែក៏បាន អាស្រ័យទៅនឹងចំណង់ចំណូលចិត្តកសិករ ប៉ុន្តែបើជីកស្រះនៅក្រៅស្រែ កសិករត្រូវជីកកូនប្រឡាយតភ្ជាប់ពីស្រះទៅស្រែនោះ (សូមមើលរូបភាពខាងក្រោម)។ ស្រះដែលតភ្ជាប់ទៅវាលស្រែ អាចមានទំហំប៉ុនណាក៏បាន និងគួរមានជម្រៅ ២ ម៉ែត្រ។ ការចិញ្ចឹមត្រីក្នុងស្រែ ឬស្រះភ្ជាប់ទៅស្រែ ធ្វើឱ្យត្រីលូតលាស់បានល្អ ដោយសារត្រីចេញពីស្រះទៅរកចំណីក្នុងស្រែ ហើយត្រីនឹងត្រឡប់មក

ស្រះវិញ នៅពេលទឹកក្នុងស្រែរាក់ ឬទឹកស្រែមានកំដៅក្តៅ។ ជាទូទៅ នៅពេលប្រមូលផលស្រូវ ទឹកក្នុងស្រែត្រូវបានបូមពង្រីង ហើយត្រីនឹងទៅប្រមូលផ្តុំគ្នាក្នុងស្រះ ដែលធ្វើឱ្យកសិករងាយស្រួលប្រមូលផល។

កូនប្រឡាយតភ្ជាប់ពីស្រះទៅស្រែ



## ២.៥- ការចិញ្ចឹមត្រីក្នុងស្រែ និងការគ្រប់គ្រង

### ២.៥.១- ការរៀបចំស្រះ និងស្រែ មុនដាក់ត្រីចិញ្ចឹម

ស្រះក្នុងស្រែចិញ្ចឹមត្រីចាំបាច់ត្រូវរៀបចំ ដូចស្រះចិញ្ចឹមត្រីដែរ ដើម្បីធានាដល់ការលូតលាស់ត្រីបានល្អ។ ចំណែកដីស្រែក៏តម្រូវឱ្យរៀបចំសំអាតស្មៅ និងរុក្ខជាតិចេញពីស្រែឱ្យអស់ ព្រោះវាស្រូបយកសារធាតុចិញ្ចឹមពីដីស្រែដែលធ្វើឱ្យស្រូវលូតលាស់មិនបានល្អ មិនតែប៉ុណ្ណោះវាដណ្តើមសារធាតុចិញ្ចឹមពីត្រីផងដែរ។

#### ២.៥.១.១- ការសំអាតស្មៅ និងរុក្ខជាតិក្នុងស្រែ

ស្មៅ និងរុក្ខជាតិទឹកក្នុងស្រែ មានប្រយោជន៍ និងគ្មានប្រយោជន៍ដល់ត្រីដែលចិញ្ចឹមក្នុងស្រែ ពីព្រោះគ្រប់ប្រភេទរុក្ខជាតិទឹកក្នុងស្រែ តែងតែស្រូបយកអុកស៊ីសែនពីមជ្ឈដ្ឋានទឹក ជាពិសេសនៅពេលយប់ ហើយបញ្ចេញមកវិញឧស្ម័នពុល (ឧស្ម័នកាបូនិច)។ ប៉ុន្តែប្រភេទរុក្ខជាតិខ្លះមានប្រយោជន៍ជាចំណីត្រី ដូចជា ត្រកួន រុក្ខជាតិបួង់តុង ស្មៅ .... ជាដើម។ បើមានស្មៅ និងរុក្ខជាតិទឹកច្រើនក្នុងស្រែ វាអាចធ្វើឱ្យទឹកស្រែស្អុយ និងនាំឱ្យខ្វះខ្យល់អុកស៊ីសែននៅពេលដែលកំពស់ទឹកក្នុងស្រែកើនឡើងលិចស្មៅ និងរុក្ខជាតិទឹកទាំងនោះ។

#### ២.៥.១.២- ការបាចកំបោរ

ក្រោយពីសំអាតស្មៅ និងរុក្ខជាតិទឹកក្នុងស្រែរួចមក កសិករត្រូវប្រើកំបោរបាចតែលើផ្ទៃប្រឡាយ និងស្រះដែលមានក្នុងស្រែចិញ្ចឹមត្រី ដើម្បីកែលំអគុណភាពទឹកក្នុងស្រែ ធ្វើឱ្យដីមានគុណភាពល្អ សម្លាប់ត្រីកាច និងមេរោគជាដើម។ មិនតែប៉ុណ្ណោះ កំបោរធ្វើឱ្យទឹកថ្លា និងអាចបង្កើនសារជាតិចិញ្ចឹមក្នុងទឹកទៀតផង។ បរិមាណកំបោរត្រូវប្រើអាស្រ័យទៅតាមប្រភេទដីដូចក្នុងតារាងខាងក្រោម:

| **កំរិត** pH | **ប្រភេទដី** | **បរិមាណកំបោរត្រូវប្រើ ( គ.ក្រ ក្នុង ១០០ម២)** |
|---|---|---|
| ៤- ៥ | អាស៊ីតខ្ពស់ | ២០ |
| ៥- ៦,៥ | អាស៊ីតមធ្យម | ១០ |
| ៦,៥- ៧,៥ | ធម្មតា | ៥ |
| ៧,៥- ៨,៥ | ជាតិបាស | ២ |
| ៨,៥- ៩,៥ | ជាតិបាស ខ្លាំង | 0 |

#### ២.៥.១.៣- ការដាក់ជី

គោលបំណងនៃការប្រើប្រាស់ជី គឺដើម្បីបង្កើនសារជាតិចិញ្ចឹមនៅក្នុងទឹក ដែលនាំឱ្យមានការលូតលាស់ដល់ដំណាំស្រូវ និងរុក្ខជាតិ សត្វប្លង់តុង និងសត្វល្អិតស្រទាប់បាត ដូចជា ខ្យង ខ្ចៅ ជាដើម ដែលជាចំណីធម្មជាតិយ៉ាងសំខាន់របស់ត្រី។ កសិករអាចប្រើប្រាស់ជី ២ ប្រភេទ គឺជីគីមី និងជីធម្មជាតិ ។ ជីគីមីមាន ដូចជា ជីអ៊ុយរ៉េ និងជីដេអាប៉េ ។ ចំណែកជីធម្មជាតិមានជីលាមកសត្វ និងជីរុក្ខជាតិបៃតង ជាដើម។ បរិមាណជី ដែលត្រូវប្រើដាក់ស្រែចិញ្ចឹមត្រី មានដូចខាងក្រោម ៖

- លើផ្ទៃដីស្រែ ដាក់ជីលាមកគោពី ១០០- ១៥០គ.ក្រ ក្នុង ១០០ម$^{២}$
- ក្នុងផ្ទៃស្រះ និងប្រឡាយដាក់ជីលាមកគោពី ៨០- ១០០ គ.ក្រ ក្នុង១០០ម$^{២}$ និងជីរុក្ខជាតិបៃតងពី ១០- ១៥ គ.ក្រ/ ១០០ម$^{២}$ ។

#### ២.៥.១.៤- ការគ្រប់គ្រងគុណភាពទឹក

គុណភាពទឹកមានសារៈសំខាន់ណាស់ដល់ការលូតលាស់ត្រី។ បើគុណភាពទឹកមិនល្អ ធ្វើឱ្យត្រីលូតលាស់យឺត នាំឱ្យត្រីមានសុខភាពខ្សោយ ត្រីកើតជំងឺ និងអាចស្លាប់ទៀតផង។ កត្តាសំខាន់ៗ ដែលមានឥទ្ធិពលទៅលើគុណភាពទឹក មានដូចខាងក្រោម ៖

- កំរិត pH (Potential Hydrogen)
- កំរិតរលាយខ្យល់អុកស៊ីសែនក្នុងទឹក
- កំរិតសីតុណ្ហភាពក្នុងទឹក
- និងឧស្ម័នពុល អាម៉ូនីញ៉ាក់។

### ២.៥.២- ការដាក់ត្រីចិញ្ចឹមក្នុងស្រែ

#### ២.៥.២.១- ប្រភេទត្រីដាក់ចិញ្ចឹម

ត្រីដាក់ចិញ្ចឹមក្នុងស្រែ គួរជ្រើសរើសយកប្រភេទត្រីដែលធន់នឹងការបំរែបំរួលមជ្ឈដ្ឋានទឹកក្នុងស្រែ និងមានការលូតលាស់ល្អ ក្នុងលក្ខខ័ណ្ឌបំរែបំរួលមជ្ឈដ្ឋានទឹកក្នុងស្រែដូចខាងក្រោមៈ

- ទឹករាក់ ទឹកល្អក់
- កំរិតបំរែបំរួលសីតុណ្ហភាពក្នុងទឹកមានពី ១០- ៤០ អង្សារសេ
- កំរិតរលាយអុកស៊ីសែនទាប។

ជាទូទៅ មានប្រភេទត្រីជាច្រើនដែលអាចចិញ្ចឹមក្នុងស្រែបាន ប៉ុន្តែប្រភេទត្រីដែលចិញ្ចឹមក្នុងស្រែបានល្អជាងគេមានដូចខាងក្រោម ៖

- ត្រីកាបសាមញ្ញ
- ត្រីទីឡាព្យ៉ា
- និង ប្រភេទត្រីមួយចំនួនទៀតដូចជា ត្រីឆ្ពិន ត្រីកន្ធរ និង ត្រីក្រាញ់ ជាដើម។

  

ត្រីកាបសាមញ្ញ ត្រីទីឡាព្យ៉ា ត្រីក្រាញ់

ត្រីកន្ធរ   ត្រីឆ្ពិន

**កំណត់សំគាល់** កសិករត្រូវជៀសវាងដាក់ត្រីចិញ្ចឹមប្រភេទស៊ីស្រូវជាអាហារ ដូចជា ត្រីកាបស៊ីស្មៅជាដើម ។

### ២.៥.២.២- ចំនួនកូនត្រីដាក់ចិញ្ចឹម

ការចិញ្ចឹមត្រីក្នុងស្រែ អាចដាក់ចិញ្ចឹមត្រីតែមួយប្រភេទ ឬច្រើនប្រភេទក៏បាន។ បរិមាណកូនត្រីដាក់ចិញ្ចឹមមានការខុសគ្នាទៅតាមប្រព័ន្ធចិញ្ចឹម ព្រមទាំងអាស្រ័យទៅនឹងចំនួននៃប្រភេទត្រីដាក់ចិញ្ចឹមផងដែរ។ ជាទូទៅ ចំពោះការចិញ្ចឹមត្រីក្នុងស្រែបរិមាណកូនត្រីដាក់ចិញ្ចឹមមានចំនួនតិច ព្រោះត្រីចិញ្ចឹមក្នុងស្រែពឹងផ្អែកទៅលើចំណីធម្មជាតិដែលមានក្នុងស្រែស្រាប់។ បរិមាណកូនត្រីដាក់ចិញ្ចឹម មានការប្រែប្រួលទៅតាមបច្ចេកទេសចិញ្ចឹម និងគ្រប់គ្រង។ ប៉ុន្តែជាទូទៅបរិមាណកូនត្រីដាក់ចិញ្ចឹមក្នុងស្រែមានដូចខាងក្រោម:

- ពី ០,៧៥- ២ ក្បាល ក្នុងម$^{២}$ ផ្ទៃក្រឡាប្រឡាយ និងស្រះ នៅក្នុងស្រែ (កូនត្រីមានទំហំពី ៦-១០ ស.ម)
- ពី ០,២- ០,៥ ក្បាល ក្នុងម$^{២}$ នៃផ្ទៃក្រឡាស្រែទាំងមូល (កូនត្រីមានទំងន់ពី ១០-១៥ ក្រាម)។

កូនត្រីត្រូវដាក់ចិញ្ចឹមក្នុងស្រែ ក្រោយពីស្រូវបានស្ទូងហើយ ៣ សប្តាហ៍ ដើម្បីឱ្យដើមស្រូវរឹងមាំបានល្អ។

### ២.៥.៣- ចំណី និងការផ្តល់ចំណីបន្ថែម

ជាទូទៅ ក្នុងមជ្ឈដ្ឋានស្រែ សម្បូរដោយរុក្ខជាតិ និងសត្វប្លង់តុង ព្រមទាំងសត្វស្រទាប់បាតផ្សេងទៀត ដូចជា ខ្យង ខ្ចៅ ដែលកើតនិងលូតលាស់ឡើង ដោយការដាក់ជីដើម្បីបង្កើតសារធាតុចិញ្ចឹមសម្រាប់ចិញ្ចឹម និងបន្តពូជសត្វ និងរុក្ខជាតិទឹកធម្មជាតិទាំងនេះ ។ ប្រភេទរុក្ខជាតិ និងវារីសត្វធម្មជាតិទាំងនេះ ជាចំណីមានសារៈប្រយោជន៍សំខាន់ដល់ប្រភេទត្រីដាក់ចិញ្ចឹមផ្សេងៗគ្នា។ ដូចនេះ កសិករត្រូវប្រើជីដាក់ស្រែដើម្បីបង្កើនសារធាតុចិញ្ចឹមក្នុងស្រែ។ ជាទូទៅ កសិករមានលទ្ធភាពប្រើប្រាស់ជីសរីរាង្គ ឬជីលាមកសត្វ។ ដូចនេះ កសិករអាចប្រមូលលាមកសត្វគោ ក្របី ឬលាមកជ្រូក មាន់ ទា ដាក់ក្នុងរណ្តៅធ្វើជាទឹកជី រួចដួសដាក់ក្នុងស្រះ ឬក្នុងស្រែចិញ្ចឹមត្រី។ ម្យ៉ាងទៀត កសិករអាចចិញ្ចឹមជ្រូកក្នុងទ្រុង រួចបង្ហូរជីលាមកចូលក្នុងស្រះ ឬ ស្រែក៏បាន ដើម្បីបង្កើតចំណីធម្មជាតិ។

ក្រៅពីនេះ កសិករត្រូវផ្គត់ផ្គង់ចំណីបន្ថែមខ្លះទៀតដល់ត្រី ដើម្បីឱ្យត្រីមានការលូតលាស់ឆាប់រហ័សក្នុងពេលដ៏ខ្លី។ ការផ្គត់ផ្គង់ចំណីបន្ថែមដល់ត្រី គឺមានសារៈសំខាន់ណាស់ ជាពិសេសនៅពេលចំណីធម្មជាតិក្នុងស្រែមិនមានគ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់ត្រី ឬនៅពេលដែលកូនត្រីមានទំហំកាន់តែធំ តម្រូវការបរិមាណចំណីប្រចាំថ្ងៃក៏កាន់តែច្រើន។ ការផ្តល់ចំណីបន្ថែមដល់ត្រីចិញ្ចឹមក្នុងស្រែ ដូចគ្នានឹងការផ្តល់ចំណីត្រីចិញ្ចឹមក្នុងស្រះដែរ គឺត្រូវផ្តល់ឱ្យបាន ២ ដងក្នុង ១ថ្ងៃ។ ចំណីបន្ថែមសម្រាប់ត្រីជាធម្មតា ជាប្រភេទចំណីដែលអាចរកបានក្នុងភូមិ ដូចជា កន្ទក់ ចក ជន្លេន កាកសំណល់ផ្ទះបាយ កាកសំណល់បន្លែ ត្រកួន និងកណ្តៀរជាដើម (សូមមើលរូបភាពខាងក្រោម)។ ចំណីបន្ថែមមួយចំនួន ងាយស្រួលរក ដូចជា ចក ជន្លេន ជាពិសេសកន្ទក់ជាប្រភេទចំណីបន្ថែម ដែលកសិករនិយមដាក់ឱ្យត្រីស៊ីជាងគេ។





រូបភាពប្រភេទចំណីបន្ថែមសម្រាប់ត្រី រួមមាន កន្ទក់ ចក កណ្តៀរ ជាដើម

### ២.៥.៤- ការត្រួតពិនិត្យគុណភាពទឹក

ជម្រៅទឹកជាបញ្ហាសំខាន់ នៃការចិញ្ចឹមត្រីក្នុងស្រែ ដែលទាមទារឱ្យមានជម្រៅពី ៣០- ៤០ ស.ម ជានិច្ច។ ភ្លឺស្រែ និងទឹកក្នុងស្រែ ត្រូវឧស្សាហ៍ត្រួតពិនិត្យមើលរៀងរាល់ថ្ងៃ ដើម្បីជៀសវាងទឹកលិចជ្រាបចេញពីស្រែ។ បើសង្កេតឃើញមានសង្ស័យភ្លឺស្រែកន្លែងណាមួយជ្រាបទឹកត្រូវជួសជុលវាបន្ទាន់។ ក្នុងករណីកសិករមានប្រភពទឹកបូមបញ្ចូលស្រែ ចាំបាច់ត្រូវពិនិត្យមើលទឹកនោះមានសុវត្ថិភាពដែរឬទេ ដើម្បីជៀសវាងការឆ្លងថ្នាំពុលកសិកម្ម និងជំងឺផ្សេងៗ។ នៅពេលបូមទឹកបញ្ចូលស្រែ ចាំបាច់ត្រូវប្រើតម្រងចងភ្ជាប់នឹងចុងបំពង់ទុយោចូលស្រែ ដើម្បីជៀសវាងត្រីកាចចូលស្រែស៊ីកូនត្រី។ ម្យ៉ាងទៀត ទឹកក្នុងស្រែទាមទារឱ្យមានពណ៌បៃតងដែលធ្វើឱ្យសម្បូរ សត្វ និងរុក្ខជាតិប្លង់តុង សត្វស្រទាប់បាត មានខ្យង ខ្ចៅ ជាដើម ដែលជាចំណីធម្មជាតិសំខាន់សម្រាប់ត្រី។ ចំណីធម្មជាតិទាំងនេះកើតឡើងពីការដាក់ជី ដើម្បីបង្កើតសារជាតិចិញ្ចឹមសម្រាប់ចិញ្ចឹមចំណីធម្មជាតិទាំងនេះ (មានបញ្ជាក់នៅចំណុច ២.៥.១.៣)។



ការបូមទឹកបញ្ចូលស្រែដោយមានតម្រង



គុណភាពទឹកពណ៌បៃតងសម្បូរចំណីធម្មជាតិ

### ២.៥.៥- ការគ្រប់គ្រងត្រី និងស្រូវ

កូនត្រីដាក់ចិញ្ចឹមក្នុងស្រែ ជាផ្នែកមួយនៃប្រព័ន្ធវារីវប្បកម្ម ដោយពឹងផ្អែកលើចំណីធម្មជាតិដែលមាននៅក្នុងស្រែ។ ធនធានធម្មជាតិដែលមានក្នុងមូលដ្ឋានដូចជា កាកសំណល់ផ្ទះបាយ កាកសំណល់បន្លែ ចក ជន្លេន កណ្តៀរ ដូច

មានបញ្ជាក់ក្នុងចំណុច ២.៥.៣ ជាចំណីធម្មជាតិសំខាន់សម្រាប់ត្រី ដែលប្រជាកសិករមានលទ្ធភាពរកបានឱ្យត្រីស៊ី។ ចំណីធម្មជាតិទាំងនេះជាចំណីបន្ថែមសម្រាប់ត្រី ក្រៅពីចំណីធម្មជាតិដែលមានស្រាប់ក្នុងស្រែ ហើយដែលត្រូវផ្ដល់ឱ្យត្រីស៊ីបន្ថែម ដើម្បីឱ្យត្រីឆាប់លូតលាស់បានល្អ ក្នុងរយៈពេលខ្លី។ ដើម្បីបង្កើនការលូតលាស់ដល់ត្រីផង និងស្រូវផង កសិករចាំបាច់ត្រូវប្រើជីតាមបច្ចេកទេសត្រឹមត្រូវ ដូចមានបញ្ជាក់នៅចំណុច ២.៥.១.៣ និងហាមការប្រើថ្នាំសម្លាប់សត្វល្អិតក្នុងស្រែកំពុងចិញ្ចឹមត្រី។

រយៈពេលនៃការប្រមូលផលស្រូវ ខុសពីរយៈពេលប្រមូលផលត្រី ។ ជាធម្មតា រយៈពេលប្រមូលផលស្រូវមានពី ១០០- ១៥០ ថ្ងៃ ខ្លីជាងរយៈពេលប្រមូលផលត្រី។ ដូចនេះ ក្រោយពីប្រមូលផលស្រូវហើយ ភាគច្រើនត្រីនៅមានទំហំតូចនៅឡើយ ជាពិសេសចំពោះការចិញ្ចឹមត្រីជាមួយដំណាំស្រូវស្រាល។ ដើម្បីដោះស្រាយបញ្ហានេះ កសិករត្រូវដាក់កូនត្រីចិញ្ចឹមមានទំហំធំក្រោយពេលសំណាបស្ទូងហើយរយៈពេល ៣ សប្ដាហ៍ ដើម្បីកុំឱ្យត្រីឈ្លុសដើមស្រូវរបូត។

## ២.៥.៦- ប្រភេទស្រូវ

ប្រភេទស្រូវដាំក្នុងស្រែចិញ្ចឹមត្រី ត្រូវមានទំនាក់ទំនងជាមួយរយៈពេលនៃការចិញ្ចឹមត្រី។ បើដំណាំស្រូវឱ្យផលរយៈពេលខ្លីជាង ១០០- ១២០ ថ្ងៃ នោះត្រីដែលចិញ្ចឹមក្នុងស្រែនៅមានទំហំតូចនៅឡើយ ហើយមិនអាចលក់ទៅទីផ្សារត្រីសាច់បាន។ ក្នុងករណីនេះ កសិករអាចចិញ្ចឹមត្រីបន្តទៀតក្នុងស្រែ ក្រោយពីប្រមូលផលស្រូវហើយ រហូតដល់ត្រីធំអាចលក់ទៅទីផ្សារបាន។ ដូចនេះ កសិករគួរជ្រើសរើសប្រភេទស្រូវដែលមានរយៈពេលវែងជាង ១០០ថ្ងៃ មកដាំក្នុងស្រែ ចិញ្ចឹមត្រីហើយដែលផ្ដល់ទិន្នផលខ្ពស់។ លក្ខណៈនៃស្រូវដែលផ្ដល់ទិន្នផលខ្ពស់ មានដូចខាងក្រោម ៖-

- ដើមខ្លី ដើមស្រូវរឹងមាំ
- អាចប្រើប្រាស់បានគ្រប់ប្រភេទដី
- ធន់នឹងការប្រែប្រួលនៃពន្លឺ
- ឱ្យផលក្នុងរយៈពេលខ្លី ឬ មធ្យម ពី ១០០- ១៣០ ថ្ងៃ។

ដូចនេះ ក្នុងករណីកសិករជ្រើសរើសប្រភេទស្រូវស្រាល ដែលមានរយៈពេលខ្លីមកដាំ ចាំបាច់កូនត្រីដាក់ចិញ្ចឹមត្រូវមានទំហំធំ និងត្រូវប្រមូលផលនៅក្រោយពេលប្រមូលផលស្រូវរួច។

## ២.៥.៧- ការគ្រប់គ្រងស្មៅ និងសត្វល្អិតចង្រៃក្នុងស្រែ

### ២.៥.៧.១- ការគ្រប់គ្រងស្មៅ និងសត្វល្អិតចង្រៃ ដោយមានចិញ្ចឹមត្រីក្នុងស្រែ

ការគ្រប់គ្រងស្មៅ និងសត្វល្អិតចង្រៃក្នុងស្រែចិញ្ចឹមត្រី មានវិធី ៣ យ៉ាងសំខាន់ៗ គឺ ៖ ការធ្វើដោយដៃ ការប្រើវិធីតាមទំលាប់ និងការប្រើជីវសាស្ត្រ។ ក្នុងចំណោមវិធីទាំង ៣ យ៉ាងនេះ វិធីដែលនិយមប្រើជាងគេ គឺការគ្រប់គ្រងស្មៅ និងសត្វល្អិតចង្រៃក្នុងស្រែ ដោយការធ្វើដោយដៃផ្ទាល់។ វិធីនេះប្រជាកសិករនិយមប្រើជាយូរអង្វែងមក ហើយដូចជាការដកស្មៅ និងរុក្ខជាតិចង្រៃក្នុងស្រែ។ ការប្រើវិធីតាមទម្លាប់ គឺជាការកំរិតកំណត់កំពស់ទឹកក្នុងស្រែ ដើម្បីសម្លាប់រុក្ខជាតិ និងសត្វល្អិតចង្រៃ។ ចំណែកវិធីប្រើជីវសាស្ត្រ ជាវិធីសរីរាង្គមួយដែលប្រើពួកសត្វមានប្រយោជន៍ ដើម្បីសម្លាប់សត្វល្អិតចង្រៃក្នុងស្រែ និងការប្រើប្រាស់ពូជស្រូវដែលធន់នឹងជំងឺ។

ការដាំស្រូវតែមួយមុខ ឱកាសក្នុងការសាយភាយនៃស្មៅ និងសត្វល្អិតក្នុងស្រែ មានកំរិតខ្លាំង។ ដូចនេះ ការចិញ្ចឹមត្រីក្នុងស្រែជាសកម្មភាពមួយល្អបំផុត ព្រោះវាបានបំពេញផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ដូចជា ត្រីស៊ីស្មៅ និងសត្វល្អិតចង្រៃនៅក្នុងស្រែ ដែលធ្វើឱ្យផលស្រូវកើនឡើង និងត្រីចិញ្ចឹមឆាប់ធំធាត់។

### ២.៥.៧.២- ការគ្រប់គ្រងស្មៅ និងរុក្ខជាតិចង្រៃ

មានវិធីសាស្ត្រអនុវត្តមួយចំនួន ក្នុងការកំចាត់ស្មៅ និង រុក្ខជាតិចង្រៃ ក្នុងស្រែ ដូចជា -ការរៀបចំដីស្រែ ការកំរិតកំពស់ទឹកក្នុងស្រែ ការព្យាយាមដកស្មៅ រុក្ខជាតិដោយដៃ និងការដាក់ត្រីចិញ្ចឹមប្រភេទដែលចូលចិត្តស៊ីស្មៅ រុក្ខជាតិ និងសត្វចង្រៃបំផ្លាញដំណាំស្រូវ ដូចជា ខ្យង ជាដើម ។ ខាងក្រោមនេះ ជារបៀបក្នុងការអនុវត្តៈ

- កំរិតកំពស់ទឹកក្នុងស្រែ យ៉ាងហោចណាស់ ១៥ ស.ម ដែលធ្វើឱ្យប្រភេទរុក្ខជាតិមួយចំនួនដូចជា *Echimochloa crusgalli* មិនអាចលូតលាស់បាន ហើយប្រភេទស្មៅ និងរុក្ខជាតិតូចៗដទៃទៀតនឹងត្រូវងាប់ ។ កំរិតកំពស់ទឹកនេះអាចដាក់ត្រីចិញ្ចឹមក្នុងស្រែបាន ហើយត្រីនឹងជួយបំផ្លាញស្មៅ រុក្ខជាតិ និងសត្វចង្រៃបំផ្លាញដំណាំស្រូវជាអាហាររបស់វា ។
- របៀបមួយទៀត គឺការដកស្មៅ រុក្ខជាតិ និងការចាប់យកសត្វចង្រៃបំផ្លាញដំណាំស្រូវចេញពីស្រែដោយដៃ ។ របៀបនេះត្រូវបានប្រជាកសិករនិយមប្រើ ប៉ុន្តែវាបង្កផលមិនល្អដល់ស្រែដែលមានដាក់ត្រីចិញ្ចឹម ធ្វើឱ្យត្រីលូតលាស់យឺតជាដើម ព្រោះការចុះដកស្មៅក្នុងស្រែធ្វើឱ្យទឹកស្រែល្អក់ ។ ម្យ៉ាងទៀត វិធីធ្វើដោយដៃនេះត្រូវការព្យាយាមអនុវត្តជាញឹកញាប់ ឬ ត្រូវការកម្លាំងពលកម្មច្រើន ។

### ២.៥.៧.៣- ការគ្រប់គ្រងជំងឺត្រី

ត្រីចិញ្ចឹមនៅក្នុងស្រែមានតួនាទី កំណត់នូវការរីកសាយភាយកូនរុក្ខជាតិ ខ្យង និងសត្វល្អិត ។ មានយន្តការបីយ៉ាងជួយកាត់បន្ថយនូវការប៉ះពាល់ការឆ្លងរបស់ពួកផ្សិតៈ

- ត្រីកាត់បន្ថយនូវជំងឺស្លឹកផ្នែកខាងក្រោមរបស់ដើមស្រូវ ដែលជាហេតុទប់ស្កាត់នូវប្រភពការឆ្លងនៅតាមវាលស្រែ
- ស្លឹកផ្នែកខាងក្រោមរបស់ដើមស្រូវត្រូវកាត់បន្ថយ ជួយឱ្យមានខ្យល់ និងពន្លឺគ្រប់គ្រាន់ដែលជាលក្ខខណ្ឌមិនប្រកបដល់ការកកើត និងលូតលាស់របស់ពួកផ្សិត ។
- ស្ថានភាពទឹកជ្រៅក្នុងរយៈពេលយូរ ការពារការដុះពន្លករបស់ស្ព័រ និងការឆ្លងជំងឺឡើងវិញ ។

### ២.៥.៧.៤- ការការពារជំងឺត្រី

ជាទូទៅ ក្នុងការងារអនុវត្តជាក់ស្តែង ជំងឺត្រីពុំដែលឃើញមានកើតឡើងទេ ពីព្រោះសកម្មភាពចិញ្ចឹមត្រីទោះជាក្នុងស្រះក្តី ឬក្នុងស្រែក្តី មានលក្ខណៈជាទ្រង់ទ្រាយតូច សម្រាប់ប្រើប្រាស់ជាម្ហូបអាហារប្រចាំថ្ងៃ តែប៉ុណ្ណោះ ។ ម្យ៉ាងទៀត អាកាសធាតុប្រទេសកម្ពុជាមានលក្ខណៈអំណោយផលល្អ ដល់ការអភិវឌ្ឍន៍សកម្មភាពចិញ្ចឹមត្រី ។ ទោះជាយ៉ាងណាក៏ដោយ ការចិញ្ចឹមត្រីក្នុងស្រែ កសិករត្រូវតែមានវិធានការការពារជំងឺត្រី ប្រសើរជាងការព្យាបាលជំងឺត្រី ។ ដូចនេះ ដើម្បីចិញ្ចឹមត្រីឱ្យទទួលបានជោគជ័យ កសិករត្រូវយកចិត្តទុកដាក់គ្រប់គ្រងសុខភាពត្រីឱ្យបានល្អ ដោយត្រូវចាត់វិធានការណ៍ការពារកុំឱ្យមានឆ្លងជំងឺត្រី តាមអនុសាសន៍ដូចខាងក្រោម ៖

- ត្រូវរៀបចំស្រែ ប្រឡាយ និងស្រះចិញ្ចឹមត្រីឱ្យបានល្អត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដូចបានបញ្ជាក់ ក្នុងចំណុច ២.៥.១ ខាងលើ
- ប្រភពទឹកយកមកប្រើប្រាស់ចិញ្ចឹមត្រី ត្រូវជៀសវាងមានធាតុគីមី និងថ្នាំពុល (សូមមើលបន្ថែមចំណុច២.៥.៤)

- ត្រូវរក្សាគុណភាពទឹកស្រះ ឬ ស្រែចិញ្ចឹមត្រីឱ្យបានល្អ (មានបញ្ជាក់បន្ថែមនៅចំណុច ២.៥.៤)
- កូនត្រីពូជដាក់ចិញ្ចឹមត្រូវមានសុខភាពល្អ ធន់នឹងជំងឺ និងការប៉ះប្រែប្រួលមជ្ឈដ្ឋានទឹក
- កុំប្រើប្រាស់ថ្នាំពុលកសិកម្ម ដូចជា ថ្នាំសម្លាប់សត្វល្អិត ក្នុងស្រែកំពុងចិញ្ចឹមត្រី
- ការផ្គត់ផ្គង់ចំណីបន្ថែមត្រូវមានសុវត្ថិភាពល្អ ជៀសវាងមានជាតិពុល។

## ២.៦- ការប្រមូលផលត្រី និងស្រូវ

### ២.៦.១- ការប្រមូលផលត្រី

ជាទូទៅ ការប្រមូលផលត្រីចិញ្ចឹមក្នុងស្រែ មាន ២ របៀប។ ការប្រមូលផលត្រីរបៀបទី ១ ប្រព្រឹត្តទៅនៅពេលប្រមូលផលស្រូវ ក្រោយពេលស្ទូងហើយបានរយៈពេល ៦ខែ ដែលនៅពេលនោះត្រីមានទំហំធំ អាចចាប់លក់ទៅទីផ្សារបាន។ ដូចនេះ ដើម្បីប្រមូលផលត្រីបានក្នុងពេលដំណាលគ្នា នៃការប្រមូលផលស្រូវ កសិករត្រូវដាក់កូនត្រីចិញ្ចឹមមានទំហំធំពី ៦- ១០ ស.ម ហើយក្នុងស្រែត្រូវមានទឹកគ្រប់គ្រាន់ពី ៣០- ៤០ ស.ម រយៈពេល ៦ខែ ដើម្បីឱ្យកូនត្រីឆាប់ធំធាត់។ ការប្រមូលផលត្រីរបៀបទី ២ គឺប្រព្រឹត្តទៅនៅក្រោយពេលប្រមូលផលស្រូវហើយពី ៣- ៤ ខែ ព្រោះក្រោយពេលប្រមូលផលស្រូវហើយ ត្រីនៅមានទំហំតូចនៅឡើយ ហើយកសិករអាចចិញ្ចឹមត្រីបន្តទៀតនៅក្នុងស្រែ បើក្នុងស្រែនៅមានទឹកអាចចិញ្ចឹមបាន។ ក្នុងករណីនេះ កសិករត្រូវផ្តល់ចំណីបន្ថែមដល់ត្រី ដើម្បីឱ្យត្រីឆាប់លូតលាស់បានល្អ។ ការប្រមូលផលត្រីតាមរបៀប ២ យ៉ាងខាងលើនេះ កសិករត្រូវបង្ហូរ ឬ បូមទឹកចេញពីស្រែ ពីប្រឡាយ និងពីស្រះ ដើម្បីងាយស្រួលក្នុងការប្រមូលចាប់ផលត្រីពីក្នុងស្រះ ឬប្រឡាយ។

### ២.៦.២- ការប្រមូលផលស្រូវ

ជាទូទៅ ស្រែដែលមានដាក់ត្រីចិញ្ចឹម តែងតែទទួលបានទិន្នផលស្រូវខ្ពស់ជាងស្រែ ដែលមិនមានដាក់ត្រីចិញ្ចឹម ពីព្រោះការចិញ្ចឹមត្រីក្នុងស្រែធ្វើឱ្យដីស្រែបង្កើនគុណភាព ហើយត្រីស៊ីស្មៅ និងរុក្ខជាតិចង្រៃតូចៗ ជាអាហាររបស់វា។ តាមការសិក្សាជាក់ស្តែង ដែលបានបង្ហាញនៅចំណុចខាងក្រោម ២.៨ បានបញ្ជាក់ថា ការដាក់ត្រីចិញ្ចឹមក្នុងស្រែដែល មានទំហំពី ២.០០០- ៣.០០០ម$^{២}$ បានធ្វើឱ្យទិន្នផលស្រូវកើនឡើងជាងពេលដែលមិនទាន់ដាក់ត្រីចិញ្ចឹម ហើយកសិករទទួលផលចំណេញពីផលស្រូវ និងត្រី ច្រើនជាងផលចំណេញពីស្រូវតែមួយមុខ។

## ២.៧- ការលក់ផលត្រីចិញ្ចឹម

ក្រោយការប្រមូលផលត្រី កសិករតែងតែបានបែងចែកផលត្រីសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និង សម្រាប់លក់ក្នុងភូមិ។ ជាធម្មតា ផលត្រីចិញ្ចឹមដែលទុកសម្រាប់ហូបក្នុងគ្រួសារ ក្រៅពីត្រីដែលគាត់ប្រស់ទុកសម្រាប់ហូបស្រស់រយៈពេល ៣-៤ ថ្ងៃ គាត់បានកែច្នៃជាប្រហុក ផ្អក ឬ ជាត្រីងៀត ត្រីប្រឡាក់ជាដើម សម្រាប់ទុកហូបបានរយៈពេលយូរ។

## ២.៨- ការវិភាគសេដ្ឋកិច្ច

ការចិញ្ចឹមត្រីក្នុងស្រែ តែងតែធ្វើឱ្យផលស្រូវកើនឡើង ពីព្រោះបានធ្វើឱ្យដីស្រែមានជីវជាតិ និងកំចាត់សត្វរុក្ខជាតិដែលបំផ្លាញដំណាំស្រូវ។ តាមរយៈនេះកសិករអាចបង្កើនជីវភាពរស់នៅរបស់គាត់បានល្អប្រសើរ ដោយសារការទទួលបានប្រាក់ចំណូលច្រើនពីការលក់ផលស្រូវ និងត្រី។ មិនតែប៉ុណ្ណោះ ដោយសារការចិញ្ចឹមត្រីក្នុងស្រែ កសិករសន្សំសំចៃថវិកាបានមួយកំរិតទៀត ដោយបញ្ឈប់ការចំណាយទៅលើការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតបំផ្លាញដំណាំស្រូវ និងមិនចាំបាច់

ចំណាយកម្លាំងពលកម្មដកស្ទៅស្រែឡើយ ។ ខាងក្រោមនេះ ជាករណីសិក្សាជាក់ស្តែងពីការចិញ្ចឹមត្រីក្នុងស្រែ របស់កសិករពីរគ្រួសារនៅខេត្តតាកែវ ក្នុងឆ្នាំ ២០០៥-២០០៦ ។

| បរិយាយ | កសិករទី ១<br>ផ្ទៃស្រែ = ២.០០០ ម$^2$ | កសិករ ទី ២<br>ផ្ទៃស្រែ = ៣.០០០ ម$^2$ |
|---|---|---|
| ផលស្រូវមុនពេលចិញ្ចឹមត្រីក្នុងស្រែ | ១៥៦ គ.ក្រ – ១៧ $ | ៤៨០ គ.ក្រ –៥០ $ |
| ផលស្រូវក្រោយពេលចិញ្ចឹមត្រីក្នុងស្រែ | ២៤០ គ.ក្រ – ២៦ $ | ៧២០ គ.ក្រ –៧៥ $ |
| ផលត្រីចិញ្ចឹមក្នុងស្រែ | ១១៥ គ.ក្រ – ១១៥ $ | ២០០ គ.ក្រ –២០០ $ |
| ការចំណាយលើការចិញ្ចឹមត្រីក្នុងស្រែ | ៣២ $ | ៧១,៤ $ |
| ផលចំណេញសរុបពីការចិញ្ចឹមត្រីក្នុងស្រែ | ១០៩ $ | ២០៣ $ |
| ផលធៀបប្រាក់ចំណេញរវាង:<br>ការចិញ្ចឹមត្រីក្នុងស្រែស<br>ផលស្រូវមុនពេលចិញ្ចឹមត្រីក្នុងស្រែ | ៦,៤ ដង | ៤ ដង |

តារាងខាងក្រោមនេះ ជាឧទាហរណ៍នៃការវិភាគសេដ្ឋកិច្ច ការចិញ្ចឹមត្រីក្នុងស្រែជាលក្ខណៈគ្រួសារ ទំហំ ១.០០០ ម$^2$ ភ្ជាប់ជាមួយស្រះទំហំ ១០០ ម$^2$ ដោយមានការគ្រប់គ្រងបានល្អក្នុងរយៈពេលជាង ៤ខែ ទទួលបានលទ្ធផលដូចខាងក្រោម:

| សកម្មភាព | ការចិញ្ចឹមត្រីក្នុងស្រែ តាមទំលាប់ | | | | ការចិញ្ចឹមត្រីក្នុងស្រែ តាមបច្ចេកទេស | | | |
|---|---|---|---|---|---|---|---|---|
| | ឯកត្តា | ចំនួន | តម្លៃរាយ | តម្លៃសរុប(៛) | ឯកត្តា | ចំនួន | តម្លៃរាយ | តម្លៃសរុប(៛) |
| **ការជីកស្រះ ប្រឡាយ ភ្លឺ** | | | | | | | | |
| ស្រះថ្មី | ម៣ | ៨៧ | ៣ ០០០ | ២៦១ ០០០ | ម៣ | ៨៧ | ៣ ០០០ | ២៦១ ០០០ |
| ប្រឡាយ | ម៣ | ៧,៥ | ៣ ០០០ | ២២ ៥០០ | ម៣ | ៧,៥ | ៣ ០០០ | ២២ ៥០០ |
| លើកភ្លឺស្រែ | ម៣ | ២៨ | ៣ ០០០ | ៨៤ ០០០ | ម៣ | ២៨ | ៣ ០០០ | ៨៤ ០០០ |
| សរុប | | | | **៣៦៧ ៥០០** | | | | **៣៦៧ ៥០០** |
| **ការរៀបចំស្រះ** | | | | | | | | |
| ថ្លៃឈ្នួលបូមទឹកស្រះ | ម៉ោង | ០ | ០ | ០ | ម៉ោង | ៣ | ៥ ០០០ | ១៥ ០០០ |
| កំបោរ | គ.ក្រ | ០ | ០ | ០ | គ.ក្រ | ១០ | ៥០០ | ៥ ០០០ |
| ជីលាមកសត្វ | គ.ក្រ | ៣០ | ០ | ០ | គ.ក្រ | ៣០ | ០ | ០ |
| ជីកំប៉ុស្តិ៍ | គ.ក្រ | ៥ | ០ | ០ | គ.ក្រ | ៥ | ០ | ០ |
| សរុប | | | | ០ | | | | **២០ ០០០** |
| **ការដាក់កូនត្រីចិញ្ចឹម** | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣- ៤ ប្រភេទ | ក្បាល | ៣០០ | ៥០ | ១៥ ០០០ | ក្បាល | ៣០០ | ១០០ | ៣០ ០០០ |
| សរុប | | | | ១៥ ០០០ | | | | **៣០ ០០០** |
| **ការរៀបចំស្រែ** | | | | | | | | |
| ភ្ជួររាស់ | ម៉ោង | ៨ | ០ | ០ | ម៉ោង | ៨ | ០ | ០ |
| ពូជស្រូវ | គ.ក្រ | ៥ | ០ | ០ | គ.ក្រ | ៥ | ០ | ០ |
| ស្ទូងស្រូវ | ថ្ងៃ | ១- ២ | ០ | ០ | ថ្ងៃ | ១- ២ | ០ | ០ |
| ជីកំប៉ុស្តិ៍ | គ.ក្រ | ៥០ | ០ | ០ | គ.ក្រ | ៥០ | ០ | ០ |
| ជីលាមកសត្វ | គ.ក្រ | ៣០០ | ០ | ០ | គ.ក្រ | ៣០០ | ០ | ០ |
| ការដកស្មៅ | ម៉ោង | ៣ | ០ | ០ | ម៉ោង | ៣ | ០ | ០ |
| Sub-total | | | | ០ | | | | ០ |
| **ការផ្តល់ចំណីបន្ថែម** | | | | | | | | |
| កន្ទក់ | គ.ក្រ | ១៥ | ៥៥០ | ៨ ២៥០ | គ.ក្រ | ១៥ | ៥៥០ | ៨ ២៥០ |
| ចក | គ.ក្រ | ៥០ | ០ | ០ | គ.ក្រ | ៥០ | ០ | ០ |
| កាកសំណល់បន្លែ | គ.ក្រ | ១០ | ០ | ០ | គ.ក្រ | ១០ | ០ | ០ |
| សរុប | | | | ៨ ២៥០ | | | | ៨ ២៥០ |
| **ការគ្រប់គ្រងស្រែះ** | | | | | | | | |
| ថ្លៃឈ្នួលបូមទឹក | ម៉ោង | ០ | ០ | ០ | ម៉ោង | ១ | ៥ ០០០ | ៥ ០០០ |
| ជីអ៊ុយរ៉េ | គ.ក្រ | ០ | ០ | ០ | គ.ក្រ | ១,៥ | ១ ៦០០ | ២ ៤០០ |
| ជីលាមកសត្វ | គ.ក្រ | ០ | ០ | ០ | គ.ក្រ | ៤០ | ០ | ០ |
| ជីកំប៉ុស្តិ៍ | គ.ក្រ | ០ | ០ | ០ | គ.ក្រ | ២០ | ០ | ០ |
| សរុប | | | | ០ | | | | ៧ ៤០០ |
| ប្រាក់ចំណាយសរុប | | | | **២៣ ២៥០** | | | | **៦៥ ៦៥០** |
| ប្រាក់ចំណូលសរុប | គ.ក្រ | ១០ | ៥ ០០០ | ៥០ ០០០ | គ.ក្រ | ៤៦ | ៥ ០០០ | ២៣០ ០០០ |
| ប្រាក់ចំណេញសរុប= ប្រាក់ចំណូលសរុប- ប្រាក់ចំណាយសរុប | | | | **២៦ ៧៥០** | | | | **១៦៤ ៣៥០** |

## ៣- វិធីសាស្ត្រផ្សព្វផ្សាយ

### ៣.១- ការសិក្សាទីផ្សារ

ការសិក្សាទីផ្សារមានតួនាទីសំខាន់ ក្នុងការកំណត់ទុនសម្រាប់រៀបចំដំណើរការផលិតកម្ម ដើម្បីទទួលបានប្រាក់ចំណេញពីផលិតកម្ម។ បើសិនផលត្រី និងស្រូវគ្មានទីផ្សារ ក្រៅពីការប្រើប្រាស់ក្នុងគ្រួសារ នោះការចិញ្ចឹមត្រីក្នុងស្រែមិនបានធ្វើឱ្យកសិករចាប់អារម្មណ៍អនុវត្តគ្រប់ៗគ្នាដែរ។ ប៉ុន្តែជាក់ស្តែងស្រូវ និងត្រីជាស្បៀងអាហារយ៉ាងសំខាន់ ដែលមិនអាចខ្វះបានក្នុងជីវភាពរស់នៅ។ ក្រៅពីការប្រើប្រាស់ក្នុងគ្រួសារ ត្រី និងស្រូវ ជាមុខទំនិញមួយយ៉ាងសំខាន់នៅលើទីផ្សារ ដែលប្រជាកសិករអាចរកប្រាក់ចំណូលបានច្រើនពីការលក់ផលិតផលត្រី និងស្រូវ។ ដូចនេះ ការចិញ្ចឹមត្រីក្នុងស្រែកំពុងទទួលការចាប់អារម្មណ៍ពីកសិករកាន់តែច្រើនឡើង។ ការរៀបចំជាបញ្ជីសំណួរជាវិធីមួយល្អ សម្រាប់ការសិក្សាទីផ្សារ។

## ៣.២- ការផ្សព្វផ្សាយបច្ចេកទេស

ការផ្សព្វផ្សាយវារីវប្បកម្ម មានតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះ និងក្នុងស្រែ។ ផ្អែកលើមូលដ្ឋានការផ្សព្វផ្សាយនេះ កសិករនឹងទទួលបានចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រីថ្មីៗ ពីក្រុមអ្នកផ្សព្វផ្សាយ ដើម្បីយកទៅអនុវត្តពង្រីកការងារវារីវប្បកម្មឱ្យបានកាន់តែល្អប្រសើរឡើង។

តារាងខាងក្រោមនេះ ជាចំណុចសំខាន់ៗ នៃសកម្មភាពផ្សព្វផ្សាយ។ ចំណុចសំខាន់នីមួយៗ នឹងធ្វើការបកស្រាយលំអិតដូចខាងក្រោម ។




### ការជ្រើសរើសទីកន្លែង

ការជ្រើសរើសទីកន្លែងដើម្បីអភិវឌ្ឍសកម្មភាពចិញ្ចឹមត្រីក្នុងស្រែជាកត្តាសំខាន់ក្នុងការកំណត់នូវភាពជោគជ័យរបស់គម្រោង ហើយជាទូទៅអាចអនុវត្តចាប់ពីខែ មីនា ដល់ខែ មេសា។ ខាងក្រោមនេះ ជាលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីកន្លែង ដើម្បីអភិវឌ្ឍន៍សកម្មភាពចិញ្ចឹមត្រីក្នុងស្រែ (មានបង្ហាញលំអិតនៅមេរៀន ២. ២)។

- ផលត្រីស្រែមិនអាចផ្គត់ផ្គង់តាមតម្រូវការប្រើប្រាស់របស់ប្រជាកសិករក្នុងមូលដ្ឋាន
- ប្រជាកសិករខ្វះអាហារូបត្ថម្ភ

- មានកសិករគ្រីក្រច្រើនក្នុងមូលដ្ឋាន ចាប់អារម្មណ៍ការងារបច្ចេកទេសចិញ្ចឹមត្រី ហើយពុំដែលបានទទួលការងារបណ្តុះបណ្តាលពីក្រុមអ្នកផ្សព្វផ្សាយ
- មានកសិករដែលមានលទ្ធភាពអនុវត្តការងារផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី
- រដ្ឋអំណាចក្នុងមូលដ្ឋាន ចាប់អារម្មណ៍ និងគាំទ្រដល់ការងារអភិវឌ្ឍន៍វារីវប្បកម្ម
- មានប្រភពទឹកដែលអាចចិញ្ចឹមត្រីក្នុងស្រែបាន យ៉ាងហោចណាស់រយៈពេល ៤ ខែ
- ជាតំបន់មិនលិចទឹកខ្លាំងនៅរដូវវស្សា
- ជាតំបន់សម្បូរវាលស្រែសមស្រប សម្រាប់ផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ។

**ការរៀបចំសិក្ខាសាលាកសិករ**

ការរៀបចំសិក្ខាសាលាកសិកររៀបចំឡើង ដើម្បីធានាដល់ភាពជោគជ័យក្នុងការធ្វើបង្ហាញ និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ ដែលត្រូវចាប់ផ្តើមអនុវត្តពីខែ ឧសភា ឬ អាចចាប់ផ្តើមនៅមុខខែ ឧសភា ក៏បាន នៅពេលទឹកក្នុងស្រែមានគ្រប់គ្រាន់សម្រាប់ដាក់កូនត្រីចិញ្ចឹម។ សិក្ខាសាលានេះរៀបចំឡើង ដើម្បីប្រមូលព័ត៌មាន និងពិភាក្សាជាមួយកសិករអំពីលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីកន្លែង និងកសិករ ដើម្បីផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ ព្រមទាំងផ្តល់ព័ត៌មានទៅកសិករវិញអំពីយុទ្ធសាស្ត្រនៃការអភិវឌ្ឍសកម្មភាពចិញ្ចឹមត្រីក្នុងស្រែ នៅក្នុងតំបន់។

**ការរៀបចំផែនការសកម្មភាព**

ផែនការសកម្មភាពចិញ្ចឹមត្រីក្នុងស្រែ នឹងត្រូវបានរៀបចំសម្រេច នៅក្រោយពេលសិក្ខាសាលាកសិកររួច ដោយផ្អែកលើលទ្ធផលសិក្ខាសាលាដែលបានពិភាក្សាជាមួយកសិករ។ ផែនការសកម្មភាពនេះនឹងរៀបរាប់សកម្មភាពសំខាន់ៗជាលំដាប់លំដោយ តាំងពីសកម្មភាពចាប់ផ្តើមដំបូង រហូតដល់បញ្ចប់សកម្មភាពជាយុទ្ធសាស្ត្រ ដោយមានបញ្ជាក់ពីពេលវេលាដែលត្រូវអនុវត្តដូចខាងក្រោម។ សកម្មភាពខ្លះ ក្នុងផែនការនេះអាចមានការផ្លាស់ប្តូរ អាស្រ័យដោយពេលវេលាមានភ្លៀងធ្លាក់គ្រប់គ្រាន់។

| សកម្មភាព | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ការជ្រើសរើសទីកន្លែង | | | | | | | | | | | | |
| ការរៀបចំសិក្ខាសាលាកសិករ | | | | | | | | | | | | |
| ការរៀបចំផែនការ | | | | | | | | | | | | |
| ការជ្រើសរើសកសិករ | | | | | | | | | | | | |
| រៀបចំធ្វើបង្ហាញការចិញ្ចឹមត្រីក្នុងស្រែ | | | | | | | | | | | | |
| ផ្តល់វគ្គបណ្តុះបណ្តាល | | | | | | | | | | | | |
| ផ្តល់សំភារៈខ្លះៗ សម្រាប់អនុវត្ត | | | | | | | | | | | | |
| តាមដានសកម្មភាព និងផ្សព្វផ្សាយ | | | | | | | | | | | | |
| វាយតម្លៃ និងធ្វើរបាយការណ៍ | | | | | | | | | | | | |
| រៀបចំសិក្ខាសាលាកសិករបញ្ចប់ | | | | | | | | | | | | |
| រៀបចំផែនការអនុវត្តបន្ត | | | | | | | | | | | | |
| ជ្រើសរើសកសិករផលិតកូនត្រីពូជ | | | | | | | | | | | | |

**ការជ្រើសរើសកសិករ**

ការជ្រើសរើសកសិករ ត្រូវចាប់ផ្តើមអនុវត្តភ្លាម ក្រោយពេលរៀបចំផែនការសម្រេចហើយ ជាពិសេសនៅមុនពេលមានភ្លៀងធ្លាក់គ្រប់គ្រាន់ក្នុងស្រែដែលអាចដាក់ត្រីចិញ្ចឹមបាន បើមិនដូចនេះទេកសិករមិនអាចចិញ្ចឹមត្រីក្នុងស្រែបានល្អឡើយ ។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករ ត្រូវផ្អែកលើមេរៀនខាងលើនៅចំណុចទី ២.៣ និងយោងតាមព័ត៌មានប្រមូលបានពីសិក្ខាសាលាកសិករ ។

**ការរៀបចំធ្វើបង្ហាញសកម្មភាពចិញ្ចឹមត្រីក្នុងស្រែ**

ជាដំបូងត្រូវរៀបចំផែនការសម្រាប់ដំណើរការសកម្មភាព ដោយប្រើប្រាស់ស្រែកសិករដែលយើងបានជ្រើសរើស ។ ដើម្បីដំណើរការសកម្មភាពនេះឱ្យមានប្រសិទ្ធិភាព អ្នកផ្សព្វផ្សាយត្រូវរើសយកកសិករពី ៥-១០ គ្រួសារ ក្នុងភូមិតែមួយ ដោយប្រើវិធីសាស្ត្រជ្រើសរើសកសិករ ដែលបានរៀបរាប់នៅចំណុច ២.៣ ។

**ការផ្តល់វគ្គបណ្តុះបណ្តាល**

ក្រោយពេលរៀបចំចងក្រងក្រុមកសិករធ្វើបង្ហាញ ត្រូវផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែដល់ក្រុមកសិករដែលបានជ្រើសរើស ដោយយកចំណុចសំខាន់ៗនៃមេរៀនបច្ចេកទេស ដែលបានរៀបរាប់ក្នុងសៀវភៅគោលការណ៍ណែនាំបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែនេះមកបង្រៀន ។ វគ្គបណ្តុះបណ្តាលនេះត្រូវរៀបចំនៅកន្លែងអនុវត្តផ្ទាល់ (ស្រែចិញ្ចឹមត្រី) ដើម្បីងាយស្រួលរៀបចំសកម្មភាពអនុវត្តជាក់ស្តែង ។ ក្រៅពីនេះ ត្រូវរៀបចំផ្ទាំងរូបភាព និងសៀវភៅបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ សម្រាប់បង្ហាញ និងចែកឱ្យកសិករនៅពេលបង្រៀន ។ម្យ៉ាងទៀត គួរអញ្ជើញរដ្ឋអំណាចក្នុងមូលដ្ឋានចូលរួមបើកវគ្គបណ្តុះបណ្តាល ដើម្បីបង្កើនការងារផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ ឱ្យបានទូលំទូលាយទាំងក្នុងមូលដ្ឋាន និងនៅក្រៅមូលដ្ឋាន ។

**ការផ្តល់សំភារៈខ្លះៗសម្រាប់អនុវត្ត**

ការផ្តល់សំភារៈខ្លះៗ (សំភារៈដែលកសិករមិនមាននៅក្នុងតំបន់) សម្រាប់ការធ្វើបង្ហាញបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែដល់កសិករដែលបានជ្រើសរើស ជាវិធីមួយល្អដើម្បីលើកទឹកចិត្តដល់កសិករឱ្យខិតខំយកចិត្តទុកដាក់អនុវត្តបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែដែលគម្រោងផ្តល់ឱ្យ និងជួយផ្សព្វផ្សាយបទពិសោធន៍នេះដល់កសិករដទៃទៀតនៅក្នុងភូមិ និងនៅក្រៅភូមិ ។ ប្រភេទសំភារៈដែលគួរផ្តល់ឱ្យ ដោយគម្រោងមាន:

- កូនត្រីពូជ
- ជីគីមី ដូចជា ជីអ៊ុយរ៉េ
- ថ្លៃឈ្នួលបូមទឹក ។

គួរកត់សំគាល់ថា ការផ្គត់ផ្គង់សំភារៈខ្លះៗដល់កសិករនេះ គួរផ្តល់ឱ្យនៅឆ្នាំទី ១ ប៉ុណ្ណោះ ដើម្បីឱ្យកសិករប្រឹងប្រែងធ្វើសកម្មភាពផ្សព្វផ្សាយ ប្រឹងប្រែងរកចំណូល ដើម្បីមានទុនសម្រាប់បន្តអនុវត្តសកម្មភាពនៅឆ្នាំបន្តបន្ទាប់ទៀត ។

មធ្យោបាយ និងសំភារៈដែលកសិករត្រូវមាន:

- ស្រែចិញ្ចឹមត្រី
- ស្រះចិញ្ចឹមត្រី
- ជីធម្មជាតិ ឬ ជីសរីរាង្គ (ជីលាមកសត្វ)
- ចំណីសម្រាប់ត្រី (កន្ទក់ ចក ជន្ទេន កណ្ដៀរ
- កម្លាំងពលកម្មមើលគ្រប់គ្រងស្រែ ភ្លឺស្រែ ស្រះត្រី

**ការចុះពិនិត្យសកម្មភាពចិញ្ចឹមត្រីក្នុងស្រែរបស់កសិករ និងផ្សព្វផ្សាយបច្ចេកទេស**

ការចិញ្ចឹមត្រីក្នុងស្រែជាសកម្មភាពមួយថ្មី សម្រាប់កសិករនៅតាមជនបទ ជាពិសេសកសិករដែលពុំមានបទពិសោធន៍ចិញ្ចឹមត្រី។ ដូចនេះនៅឆ្នាំទី ១ ទាមទារឱ្យមានការធ្វើបង្ហាញ និងឱ្យគាត់បានអនុវត្តជាក់ស្ដែង រហូតគាត់អាចអនុវត្តបានដោយខ្លួនឯង។ ម្យ៉ាងទៀត ទោះបីជាកសិករបានទទួលការបណ្ដុះបណ្ដាលក៏ដោយ ក៏អ្នកផ្សព្វផ្សាយ ត្រូវឧស្សាហ៍ចុះត្រួតពិនិត្យសកម្មភាពចិញ្ចឹមត្រីរបស់កសិករ ដើម្បីផ្ដល់ដំបូន្មានបច្ចេកទេសបន្ថែមដល់គាត់ ធ្វើយ៉ាងណាឱ្យគាត់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការចិញ្ចឹមត្រីក្នុងស្រែឱ្យបានជោគជ័យ។ ខាងក្រោមនេះ ជាភារៈកិច្ចមួយចំនួនរបស់អ្នកផ្សព្វផ្សាយដែលគួរយកចិត្តទុកដាក់ដូចជា:

- ចុះពិនិត្យ ដើម្បីវាយតម្លៃសមត្ថភាពកសិករ ក្នុងការអនុវត្តបទដ្ឋានបច្ចេកវិទទដ្ឋានបច្ចេកវិទ្យាស្ដីពីការចិញ្ចឹមត្រីក្នុងស្រែ ដោយស្វែងរកបញ្ហាបច្ចេកទេសឱ្យឃើញ និងផ្ដល់វិធានការណ៍ដល់កសិករ ដើម្បីដោះ ស្រាយ។ អ្នកផ្សព្វផ្សាយ គួរចុះជួយផ្ដល់ដំបូន្មានដល់កសិករ ឱ្យបានយ៉ាងហោចណាស់មួយដង ក្នុងមួយសប្ដាហ៍ ។
- គួរផ្ដល់សៀវភៅសម្រាប់ឱ្យកសិករកត់ត្រា គ្រប់ព័ត៌មានដែលជាបញ្ហា និងការរីកចំរើន ដើម្បីងាយស្រួលក្នុងការវាយតម្លៃសមត្ថភាពការយល់ដឹងរបស់កសិករ
- ក្នុងពេលចុះពិនិត្យ អ្នកផ្សព្វផ្សាយគួរកត់ត្រាគ្រប់ព័ត៌មាន ទាំងបញ្ហាកសិករបានជួបប្រទះ និងសកម្មភាពរីកចម្រើន ដើម្បីងាយស្រួលវាយតម្លៃសមត្ថភាព និងផ្ដល់ដំបូន្មានកសិករនៅពេលក្រោយ។
- ត្រួតពិនិត្យគុណភាពទឹក និងសកម្មភាពត្រីក្នុងស្រះ- ស្រែ ដោយដាក់ចំណីឱ្យស៊ី
- អ្នកផ្សព្វផ្សាយត្រូវព្យាយាមរកឱ្យឃើញនូវបញ្ហាដែលកំពុងកើតមាន និងនឹងត្រូវកើតមាននៅពេលក្រោយព្រមទាំងមូលហេតុដែលនាំឱ្យកើតមានបញ្ហា។
- គ្រប់បញ្ហាទាំងអស់ដែលរកឃើញ អ្នកផ្សព្វផ្សាយត្រូវព្យាយាមរកឱ្យឃើញនូវដំណោះស្រាយ ហើយពន្យល់កសិករឱ្យបានយល់ច្បាស់។
- អ្នកផ្សព្វផ្សាយត្រូវរៀបចំរបាយការណ៍សង្ខេបពីលទ្ធផលសកម្មភាពចិញ្ចឹមត្រីក្នុងស្រែរបស់កសិករ សម្រាប់ធ្វើបទបង្ហាញនៅពេលសិក្ខាសាលាកសិករ ដើម្បីឱ្យកសិករបានដឹង និងរៀនសូត្រពីគ្នាទៅវិញទៅមក នៅពេលចុងបញ្ចប់សកម្មភាពចិញ្ចឹមត្រីក្នុងស្រែ ដែលជាធម្មតាច្រើនធ្វើនៅក្នុងខែ មិនា ឬ ខែមេសា ។
- ក្នុងករណីចាំបាច់ បើអ្នកផ្សព្វផ្សាយចង់ផ្ដល់ព័ត៌មាន ឬដោះស្រាយបញ្ហាបច្ចេកទេសអ្វីមួយដល់កសិករ សិក្ខាសាលានេះអាចរៀបចំធ្វើនៅពេលណាមួយក៏បានក្នុងអំឡុងពេលកំពុងអនុវត្តសកម្មភាពចិញ្ចឹមត្រីក្នុងស្រែ ។

### ការវាយតម្លៃ និងធ្វើរបាយការណ៍

តាមរយៈការចុះពិនិត្យសកម្មភាពកសិករនេះ អ្នកផ្សព្វផ្សាយអាចធ្វើការវាយតម្លៃពីបញ្ហាបច្ចេកទេស និង បញ្ហាផ្សេងៗទៀតដែលកសិករបានជួបប្រទះ ការរីកចម្រើនការយល់ដឹង និងផែនការកសិករដែលត្រូវអនុវត្តបន្ត ។ បន្ទាប់មក អ្នកផ្សព្វផ្សាយអាចរៀបចំផែនការសកម្មភាពជាមួយកសិករ ដែលត្រូវអនុវត្តបន្តនៅឆ្នាំក្រោយ ។

### ការរៀបចំសិក្ខាសាលាកសិករ

ការរៀបចំសិក្ខាសាលាបញ្ចប់មួយរដូវនៃសកម្មភាពចិញ្ចឹមត្រីក្នុងស្រែ ជាទូទៅច្រើនធ្វើនៅក្រោយពេលប្រមូលផលត្រី និងស្រូវរួច ដើម្បីផ្តល់ឱកាសឱ្យកសិករបានរៀនសូត្របន្ថែម ដោយការពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ចំណេះដឹងពីគ្នាទៅវិញ ទៅមក ដើម្បីបង្កើនសមត្ថភាព និងការយល់ដឹងបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែនៅឆ្នាំបន្តបន្ទាប់ឱ្យបានកាន់តែល្អប្រសើរ។ ក្នុងឱកាសសិក្ខាសាលានេះ អ្នកផ្សព្វផ្សាយត្រូវធ្វើបទបង្ហាញពីលទ្ធផលដែលបានរកឃើញ (បញ្ហា ដំណោះស្រាយ និងការរីកចម្រើន) និងវាយតម្លៃនៅពេលបានចុះពិនិត្យសកម្មភាពកសិករ។ នៅចុងបញ្ចប់នៃសិក្ខាសាលា យើងនឹងទទួលបានដំណោះស្រាយបញ្ហា និងផែនការសកម្មភាពអនុវត្តបន្ត ដោយមានការចូលរួមពិភាក្សា និងឯកភាពពីកសិករ ។

### ការរៀបចំផែនការសកម្មភាពនៅឆ្នាំបន្ទាប់

ក្រោយពីសិក្ខាសាលាកសិករចប់ អ្នកផ្សព្វផ្សាយនឹងទទួលបានគ្រប់ព័ត៌មានដែលទាក់ទងនឹងភាពរីកចំរើន ភាពខ្សោយ និងតម្រូវការកសិករ អនុសាសន៍ និងផែនការសកម្មភាពរបស់កសិករដែលត្រូវអនុវត្តបន្ត រួចបញ្ចូលទៅក្នុងផែនការសកម្មភាពរួមមួយសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់ ។

### ការជ្រើសរើសកសិករផលិតកូនត្រីពូជ

នៅពេលសកម្មភាពចិញ្ចឹមត្រីត្រូវបានអភិវឌ្ឍកសិករនឹងជួបបញ្ហាការខ្វះកូនត្រីពូជសម្រាប់ដាក់ចិញ្ចឹម។ ដូចនេះ ការជំរុញការងារអភិវឌ្ឍន៍បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះក្តី ក្នុងស្រែក្តីក៏អាស្រ័យនឹងលទ្ធភាពនៃការផ្គត់ផ្គង់កូនត្រីពូជផងដែរ។ ដើម្បីដោះស្រាយបញ្ហានេះ អ្នកផ្សព្វផ្សាយត្រូវជ្រើសរើសកសិករចិញ្ចឹមត្រីណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រួចធ្វើការបណ្តុះបណ្តាលសមត្ថភាពបច្ចេកទេសផលិតកូនត្រីពូជ ដើម្បីឱ្យគាត់អាចផលិតកូនត្រីពូជបានច្រើន ចែកផ្សព្វផ្សាយដល់កសិករដទៃទៀតបានគ្រប់ទីកន្លែង ។ ខាងក្រោមនេះ ជាលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករផលិតកូនត្រីពូជ ៖

**បុគ្គលិកលក្ខណៈ**

- ពេញចិត្តនឹងមុខរបរផលិតកូនត្រីពូជ
- មានចរិកតស៊ូ ឧស្សាហ៍ព្យាយាម និងមានបទពិសោធន៍ចិញ្ចឹមត្រីច្រើន
- មានសណ្តានចិត្តអាធ្យាស្រ័យល្អ មានការសហការល្អជាមួយមន្ត្រីគម្រោង
- និងសកម្មក្នុងការងារផ្សព្វផ្សាយចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រីបន្តទៅកសិករដទៃទៀត។

**ធនធានតម្រូវការ**

- មានផ្ទៃដីទូលាយអាចពង្រីកស្រះចិញ្ចឹមត្រី សម្រាប់ផលិតកូនត្រីពូជបាន
- មានប្រភពទឹកគ្រប់គ្រាន់ពេញមួយឆ្នាំ ដូចជា ស្រះទឹកធំ អណ្តូងទឹក ប្រឡាយ ជាដើម

- មានកម្លាំងពលកម្មគ្រប់គ្រាន់
- មានទុនផ្ទាល់ខ្លួនសម្រាប់ចំណាយលើសកម្មភាពផលិតកូនត្រីពូជ
- ក្នុងភូមិមានធនធានធម្មជាតិ សម្រាប់ប្រើប្រាស់ជាចំណីត្រី ដូចជា ចក ជន្លេន កណ្ដៀរ.... រុក្ខជាតិបៃតង
- មានលាមកគោ ក្របី ជ្រូក ឬ លាមក មាន់ ទា សម្រាប់ប្រើជាជី ដាក់ស្រះត្រី
- មានអាងបង្កាត់ ភ្ញាស់កូនត្រីពូជ និងមានម៉ាស៊ីនបូមទឹក
- មានត្រីមេពូជសម្រាប់បង្កាត់ ភ្ញាស់
- គ្មានមុខរបរចិញ្ចឹមជីវិតសំខាន់ណាមួយក្នុងគ្រួសារ ដែលនាំឱ្យរវល់ជាប់រហូត ។

## ៣.៣- ការចំណាយសម្រាប់ការធ្វើបង្ហាញ

វិធីសាស្ត្រផ្សព្វផ្សាយដែលបានលើកយកមកបង្ហាញ មានកម្មវិធីទូលំទូលាយ ហើយដែលទាក់ទងគ្នារវាងអ្នកផ្សព្វផ្សាយ និងកសិករ ព្រមទាំងពេលវេលាសម្រាប់ធ្វើការផ្សព្វផ្សាយបង្ហាញនូវបច្ចេកទេសថ្មីៗ ។ ចំពោះគំរូសៀវភៅផ្សព្វផ្សាយបច្ចេកទេសនេះ ការចំណាយសម្រាប់ការអនុវត្តធ្វើបង្ហាញ មានសង្ខេបដូចក្នុងតារាងខាងក្រោម ៖

| | សកម្មភាព | ចំនួន-តម្លៃ |
|---|---|---|
| ក | ក្រុមកសិករ | ៣០ នាក់ |
| ខ | ទុនចូលរួមពីកសិករគំរូ | កម្លាំងពលកម្ម ស្រះចិញ្ចឹមត្រី ចំណីត្រី ជីធម្មជាតិ |
| គ | ទុនសម្រាប់ទីតាំងធ្វើបង្ហាញ | $ ៦០ |
| ឃ | ឯកសារសម្រាប់ការបណ្ដុះបណ្ដាលក្រុមកសិករ | $ ៣០ |
| ង | ការបណ្ដុះបណ្ដាលក្រុមកសិករ- អាហារសំរ៉ន់ | $ ៩០ |
| ច | ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រី- អាហារសំរ៉ន់ | $ ២៥ |
| ឆ | ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រី- សំភារៈ | $ ១០ |
| ជ | មន្ត្រីកសិកម្មស្រុក- ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ | $ ៤២ |
| ឈ | មន្ត្រីកសិកម្មស្រុក- ប្រាក់ឧបត្ថម្ភថ្លៃធ្វើដំណើរ | $ ២៤ |
| ញ | ការចុះត្រួតពិនិត្យ<br>តាមដាននៅមូលដ្ឋានដោយអ្នកឯកទេសជំនាញ | $ ២០ |
| | សរុប | $ ៣០១ |

### សេចក្ដីបញ្ជាក់ ដោយសន្ទត់

ក- មានក្រុមកសិករ ៣០ នាក់ និងកសិករគំរូ ២ នាក់ ដែលមានទីកន្លែងធ្វើបង្ហាញការចិញ្ចឹមត្រីក្នុងស្រែចំនួន ២ កន្លែង

ខ- ទុនចូលរួមពីកសិករ (សម្រាប់ ១ កន្លែង) មានស្រែទំហំ ១.០០០ម$^{២}$ និងស្រះទំហំ ១០០ម$^{២}$ កម្លាំងពលកម្ម ចំណីត្រី (កន្ទក់ ចុងអង្ករ ចកបាយទា កណ្ដៀរ ជន្លេន ....) និងជីធម្មជាតិ (លាមកគោ ក្របី ជ្រូក មាន់ ទា)

គ- ទុនសម្រាប់ធ្វើបង្ហាញការចិញ្ចឹមត្រីក្នុងស្រែ១ កន្លែង ដោយមានរួមបញ្ចូលៈ

- ការរៀបចំស្រះ និងស្រែ សរុបទំហំ ២០០ម$^{២}$= **$១០**
- កូនត្រីដាក់ចិញ្ចឹម ៣ក្បាល/ម$^{២}$ x ១០០ម$^{២}$ x ១០០៛/ ក្បាល = **$៨** - ចំណីត្រី =4៥ -ជីគីមី = **$២**
- ការដឹកជញ្ជូន = **$៥** -សរុបទាំងអស់ = **$៣០** ។ ដូចនេះ ការធ្វើបង្ហាញ ២ កន្លែង អស់ប្រាក់ **$៦០** ។

ឃ- ឯកសារបណ្តុះបណ្តាលបច្ចេកទេសរួមមាន សំភារៈសម្រាប់បង្រៀន - មេរៀន - ការបញ្ចាំងស្លាយ -និងផ្ទាំងរូបភាពធំៗ ដែលជាដំណើរការវិធីសាស្ត្របង្រៀន ។

ង- ការបណ្តុះបណ្តាលក្រុមកសិករមាន ២ វគ្គ មួយវគ្គមានរយៈពេល ២ ថ្ងៃ

ច- ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រីក្នុងស្រែ មានកន្លះថ្ងៃ មានតែម្តងក្នុងវគ្គណាមួយ ក្នុងចំណោម ២ វគ្គ និងត្រូវមានការចូលរួមពីកសិករនៅក្បែរៗភូមិប្រហែល ៤០- ៦០ នាក់ ។

ឆ- សំភារៈសម្រាប់ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រីក្នុងស្រែ រួមមាន ឧឃោសនស័ព្ទ (មេក្រូ) ផ្ទាំងក្រដាសផ្លាស្ទិក និងផ្ទាំងបដារូបភាពផ្សេងៗ ។

ជ- សម្រាប់មន្ត្រីកសិកម្មស្រុក ថវិកាឧបត្ថម្ភរួមមាន ៤ ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងធ្វើបង្ហាញ ការចាប់ផ្តើមការត្រួតពិនិត្យតាមដាន ។ ចំពោះការបណ្តុះបណ្តាលសម្រាប់ ២ វគ្គ ផ្តល់ឱ្យ ៦ថ្ងៃ និង ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រីក្នុងស្រែ ផ្តល់ឱ្យ ២ថ្ងៃ-សរុប **១២ ថ្ងៃ** ។

ឈ- ប្រាក់ឧបត្ថម្ភសម្រាប់ម៉ូតូ ២ ដុល្លា សម្រាប់ ១ ថ្ងៃ ទាំងអស់ ១២ ថ្ងៃ

ញ- មន្ទីរកសិកម្មខេត្ត- អ្នកឯកទេសផ្តល់ជំនួញបច្ចេកទេស និងត្រួតពិនិត្យ —តាមដានការបណ្តុះបណ្តាល បអប សម្រាប់ការធ្វើបង្ហាញ ។

**ធនធានសំភារៈ**

ការិយាល័យវារីវប្បកម្ម នៃរដ្ឋបាលជលផល ដែលកំពុងសហប្រតិបត្តិការជាមួយបណ្តាអង្គការនានា និងជាមួយបណ្តាស្ថានីយស្រាវជ្រាវ ផលិតកូនត្រីពូជ ជាមជ្ឈមណ្ឌលផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី ផលិតកូនត្រីពូជ និងផលិតឯកសារផ្សព្វផ្សាយ ។

## ៣.៤- ការចូលរួមរបស់ស្ត្រី ក្នុងសកម្មភាពវារីវប្បកម្ម

ស្ត្រីជាធនធានមនុស្សមួយយ៉ាងសំខាន់ ក្នុងការចូលរួមផ្សព្វផ្សាយសកម្មភាពវារីវប្បកម្ម ទាំងការចិញ្ចឹមត្រី និងផលិតកូនត្រីពូជ ព្រមទាំងអនុវត្តបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែដែលមានក្នុងបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ។ ការចូលរួមរបស់ស្ត្រី ក្នុងសកម្មភាពនេះ គឺជាការចូលរួមចំណែកក្នុងការជំរុញសកម្មភាពអភិវឌ្ឍន៍វារីវប្បកម្មឱ្យទទួលបានជោគជ័យ។ ជាទូ ទៅស្ត្រីជាអ្នកជួយការងារវារីវប្បកម្មច្រើន ក្នុងការគ្រប់គ្រងសកម្មភាពចិញ្ចឹមត្រីប្រចាំថ្ងៃ។ សៀវភៅផ្សព្វផ្សាយបច្ចេកទេស នេះនឹងផ្តល់ដល់ស្ត្រី នូវការរកប្រាក់ចំណូលក្នុងគ្រួសារតាមរយៈការចិញ្ចឹមត្រីក្នុងស្រែ ដើម្បីលើកស្ទួយជីវភាពរស់នៅក្នុងការបង្កើនសារធាតុប្រូតេអ៊ីនក្នុងម្ហូបអាហារ និងផ្គត់ផ្គង់កូនចៅទៅសាលារៀន ព្រមទាំងសម្រាប់ការចំណាយផ្សេងៗទៀត ។

លើសពីនេះ ស្ត្រីមិនត្រឹមតែត្រូវចូលរួមក្នុងសកម្មភាពអនុវត្តការងារចិញ្ចឹមត្រីប៉ុណ្ណោះទេ ក៏ប៉ុន្តែសូម្បីតែសកម្មភាពវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេស ក៏ចាំបាច់ត្រូវឱ្យមានស្ត្រីចូលរួមផងដែរ ពីព្រោះជាទូទៅស្ត្រីជាអ្នកផ្សព្វផ្សាយដ៏ល្អទាំងនៅក្នុងតំបន់ និងនៅក្រៅតំបន់។ ក្នុងការងារអនុវត្តន៍ជាក់ស្តែង ស្ត្រី និងស្វាមី ជាមេគ្រួសារសំខាន់ក្នុងគ្រួសារតែងតែមានសកម្មភាពយ៉ាងសកម្មក្នុងមុខរបរកសិកម្ម ហើយសូម្បីតែកូនរបស់គាត់ក៏បានចូលរួមក្នុងការងារវារីវប្បកម្មនេះផងដែរ ដូចជា សកម្មភាពដាក់ចំណីត្រី ជាដើម។








សកម្មភាពស្ត្រីចូលរួមវគ្គបណ្តុះបណ្តាល ចូលរួមសកម្មភាពវារីវប្បកម្ម លក់ផលត្រីចិញ្ចឹម

## ៤. សេចក្តីបន្ថែម

### ៤.១- បញ្ហាដែលកើតមានក្នុងពេលចិញ្ចឹមត្រីក្នុងស្រែ និងវិធានការដោះស្រាយ

ក្នុងអំឡុងពេលចិញ្ចឹមត្រីក្នុងស្រែ ជួនកាលកសិករបានជួបប្រទះនឹងបញ្ហាបច្ចេកទេសមួយចំនួន ដែលធ្វើឱ្យត្រីឈឺ និងងាប់ ។ ខាងក្រោមនេះ ជាបញ្ហាដែលធ្វើឱ្យត្រីឈឺ និង ងាប់ និង ដំណោះស្រាយមួយចំនួន ។

| បញ្ហា | ដំណោះស្រាយបញ្ហា |
|---|---|
| ស្រែចិញ្ចឹមត្រីលិចទឹកនៅរដូវវស្សា | -រៀបចំភ្លឺស្រែឱ្យខ្ពស់ និងរឹងមាំ ឬ ព័ទ្ធសំណាញ់ ឬរបាំង ជុំវិញស្រែ |
| មិនបានយកចិត្តទុកដាក់មើលថែទាំភ្លឺស្រែ និងបំពង់បង្ហូរទឹកចេញ ចូល ស្រែ ធ្វើឱ្យត្រីស្រែចូល និងត្រីចិញ្ចឹមរួចចេញ | - ភ្លឺស្រែត្រូវរឹងមាំ ធានាមិនឱ្យលិចទឹក<br>- បំពង់បង្ហូរទឹកចេញ ចូល ស្រែ ត្រូវបិទឱ្យជិត<br>- ត្រូវឧស្សាហ៍ព្យាយាមមើលថែទាំភ្លឺស្រែជាប្រចាំ |
| មានកើតជំងឺត្រី | - ត្រូវឧស្សាហ៍ពិនិត្យសកម្មភាពត្រី គុណភាពទឹករៀងរាល់ថ្ងៃ<br>- បើសង្ស័យឃើញមានត្រីកើតជំងឺត្រូវចាប់វាចេញពីស្រែ<br>- បើមានលទ្ធភាពផ្លាស់ប្តូរទឹកក្នុងស្រែចេញខ្លះ(១ភាគ៣)<br>- និងត្រូវពិភាក្សាជាមួយអ្នកផ្សព្វផ្សាយ |
| មានត្រីច្រើនងើបនៅលើផ្ទៃទឹក នៅពេលព្រឹក | - អាចបាចទឹកស្រែដោយដៃ ឬម៉ាស៊ីនបូមទឹក |
| ប្រើថ្នាំសម្លាប់សត្វល្អិតក្នុងស្រែចិញ្ចឹមត្រី | - ត្រូវជៀសវាងការប្រើថ្នាំសម្លាប់សត្វល្អិតក្នុងស្រែ ដែល កំពុងចិញ្ចឹមត្រី |
| ខ្វះទឹកក្នុងស្រែ មិនអាចឱ្យត្រីរស់នៅបាន កសិករត្រូវបង្ខំចិត្តប្រមូល ផលត្រី | - គួរស្វែងរកប្រភពទឹកស្អាតបញ្ចូលស្រែ ដូចជា ទឹកអណ្តូង ឬទឹកប្រលាយផ្សេងៗ ដែលគ្មានជាតិពុល (ផះ និងកំរិត រលាយអុកស៊ីសែនសមស្រប)<br>- ឬ កសិករត្រូវព្យាយាមដាក់ត្រីចិញ្ចឹម មានទំហំធំ យ៉ាងហោចណាស់ ៥ ស.ម |
| ខ្វះប្រភពទឹកបញ្ចូលស្រែ នៅពេលរដូវប្រាំង | - ស្រះ និងប្រឡាយក្នុងស្រែ ត្រូវជីកឱ្យជ្រៅដែលអាចរក្សា ទឹកបានរយៈពេល ១២០ ថ្ងៃ<br>- ដាក់កូនត្រីចិញ្ចឹមមានទំហំធំ |
| មានគេលួចត្រី | - ស្រែចិញ្ចឹមត្រីគួរនៅជិត ឬជាប់ផ្ទះ ដើម្បីងាយស្រួល គ្រប់គ្រង ឬ អាចធ្វើរបងព័ទ្ធជុំវិញ ឬដាក់សំរះក្នុងស្រះ |
| មានត្រីស្រែលោតចូលស្រែចិញ្ចឹមត្រី | - ក្រោយពេលដាក់កូនត្រីចិញ្ចឹម ត្រូវកុំឱ្យមានត្រីស្រែលោត ចូលស្រះ ដោយត្រូវលើកភ្លឺស្រែឱ្យខ្ពស់ យ៉ាងហោចណាស់ ០,៥ ម៉ែត្រ |
| ខ្វះចំណីធម្មជាតិនៅក្នុងស្រែចិញ្ចឹមត្រី | -ដាក់ជីជាប់ជាប្រចាំដើម្បីឱ្យសម្បូរចំណីធម្មជាតិសម្រាប់ត្រី<br>-ដាក់ចំណីបន្ថែម |

## ៤.២- តារាងប្រមូលទិន្នន័យ

ការកត់ត្រាទិន្នន័យ មានសារៈសំខាន់ណាស់សំរាប់កត់ត្រាគ្រប់ព័ត៌មាន ដែលមានឥទ្ធិពលដល់ការអភិវឌ្ឍន៍ការចិញ្ចឹមត្រី ដូចជា ភាពរីកចំរើន បញ្ហាជួបប្រទះ ដំណោះស្រាយបញ្ហា លទ្ធភាពរបស់កសិករជាដើម ដើម្បីធ្វើការវិភាគស្វែងរកដំណោះស្រាយជាគន្លឹះ សម្រាប់រៀបចំផែនការអភិវឌ្ឍន៍នៅឆ្នាំបន្ទាប់។ ខាងក្រោមនេះ ជាតារាងសម្រាប់ប្រមូលទិន្នន័យសំខាន់ៗមួយចំនួន។

១- តើអ្នកបានជួបប្រទះបញ្ហាអ្វីខ្លះ ក្នុងពេលចិញ្ចឹមត្រីក្នុងស្រែ ? តើអ្នកបានដោះស្រាយបញ្ហានោះ យ៉ាងដូចម្តេច ?

| បញ្ហា | ដំណោះស្រាយ |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

២- តើអ្នកបានជួបប្រទះជំងឺត្រី ដែរឬទេ ? បើមាន តើប្រភេទជំងឺនោះមានលក្ខណៈយ៉ាងដូចម្តេច ?

______________________________

______________________________

______________________________

៣- តើពេលចិញ្ចឹមត្រីក្នុងស្រែ អ្នកបានផ្លាស់ប្តូរទឹកក្នុងស្រែដែរឬទេ ? បើមាន ប៉ុន្មានដង ? ______________
តើអ្នកផ្លាស់ប្តូរទឹកនៅពេលណា ? ______________________________

៤- តើអ្នកប្រើប្រាស់ប្រភពទឹកពីណា ? ______________________________

______________________________

______________________________

៥- តើស្រែចិញ្ចឹមត្រីរបស់អ្នក មានត្រីស្រែដែរឬទេ នៅពេលកំពុងចិញ្ចឹមត្រី ?

[ ] មាន [ ] គ្មាន

បើមាន តើមានប្រភេទត្រីអ្វីខ្លះ ? តើត្រីទាំងនោះចូលក្នុងស្រែបាន យ៉ាងដូចម្តេច ?

______________________________

______________________________

តើអ្នកបានដោះស្រាយបញ្ហានោះ បានយ៉ាងដូចម្តេច ?

______________________________

______________________________

៦- តើការចិញ្ចឹមត្រីក្នុងស្រែ បានផ្តល់អត្ថប្រយោជន៍ដល់អ្នក និងក្រុមគ្រួសារអ្នកដែរឬទេ ?
បើមាន  តើបានផ្តល់អត្ថប្រយោជន៍ យ៉ាងដូចម្តេចខ្លះ ?

បើគ្មាន  ចូរប្រាប់មូលហេតុ

៧- មតិ យោបល់ពីកសិករ

# តារាងតាមដានសកម្មភាពចិញ្ចឹមត្រីក្នុងស្រែ ប្រចាំថ្ងៃ

ឈ្មោះកសិករ.................................. ភូមិ............................ឃុំ............................ស្រុក............................ខេត្ត

ឈ្មោះមន្ត្រីផ្សព្វផ្សាយ.............................................

| ថ្ងៃ ខែ | ចំណី (១) | | | ជី (២) | | គុណភាពទឹក (៣) | | | | ចំនួនត្រីងាប់ (ក្បាល) (៤) | កំរិតលូតលាស់ត្រី (៥) | ជំរៅទឹក (ស.ម) (៦) | មានភ្លៀង ឬគ្មាន (៧) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រភេទ | ចំនួនដងក្នុង ១ថ្ងៃ | បរិមាណ (គ.ក្រ) | ធម្មជាតិ (គ.ក្រ) | ជីគីមី (គ.ក្រ) | pH | កំរិតអុកស៊ីសែន | អាម៉ូនីញាក់ | សីតុណ្ហភាព (អង្សារសេ) | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

**កំណត់សំគាល់** ក្នុងករណីមានបញ្ហាអ្វីមួយកើតឡើង ដោយចៃដន្យ សូមកត់ត្រាពីមូលហេតុនៃបញ្ហាទាំងនោះ

(1)______________________________

(2)______________________________

(3)______________________________